សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economique
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# តួនាទីសារការីនៅក្នុងលិខិតមតកសាសន៍

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ឡុច ម៉ាលី**
**ពៅ រស្មី**

សាស្រ្តាចារ្យណែនាំ
លោក **គង់ សុភ័ក្រ្ត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្រ្ត**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ឡុច ប៉ាលី** និងឈ្មោះ **ពៅ រស្មី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨-២០១៩។

**សូមសម្ដែងនូវការវេចិត្តគោរពដឹងគុណដ៏ខ្ពង់ខ្ពស់ជាអនេកប្បការជូនចំពោះ៖**

- **លោកឪពុក៖ ចាន់ ថាវី និង អ្នកម្ដាយ៖ សៅ ពៅ**
- **លោកឪពុក៖ ពៅ ពឿន និង អ្នកម្ដាយ៖ សាន គីមឈាង**

ដែលបានផ្ដល់កំណើត និងបានខិតខំពុះពារគ្រប់ឧបសគ្គក្នុងការចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ និងបានផ្គត់ផ្គង់កូនគ្រប់សព្វបែបយ៉ាងទាំងសម្ភារសម្រាប់ប្រើប្រាស់រៀនសូត្រ និងស្មារតីដល់កូន ជាពិសេសលោកទាំងទ្វេបានខិតខំជំរុញឱ្យកូនបានសិក្សារៀនសូត្ររហូតមកដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។ គុណូបការៈដែលលោកទាំងទ្វេបានផ្ដល់ និងលះបង់នេះ វាជាវត្ថុដ៏មានតម្លៃបំផុតដែលមិនអាចកាត់ថ្លៃបាន និងមិនអាចរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។ ហើយគ្មានថ្ងៃណាដែលកូនបានតបស្នងសងគុណលោកវិញអស់ឡើយ។

យើងខ្ញុំសូមសម្ដែងនូវការដឹងគុណយ៉ាងជ្រាវជ្រៅផងដែរចំពោះ៖

- **ឯកឧត្ដម លុយ ចណ្ណា សាកលវិទ្យាធិការ និង ព្រមទាំង សាកលវិទ្យាធិការរង ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងបុគ្គលិក** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ-សេដ្ឋកិច្ចទាំងអស់ដែលបានជួយតម្រង់ទិសដៅក្នុងការសិក្សារៀនសូត្ររហូត ដល់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

- ជាពិសេស **លោកសាស្ត្រាចារ្យ គង់ សុភ័ក្ត្រ** ដែលបានដឹកនាំ ចង្អុលបង្ហាញ និងសម្របសម្រួល ផ្ដល់ដំបូន្មាន និងអនុសាសន៍ល្អៗ ព្រមទាំងពន្យល់ពីវិធីសាស្ត្រក្នុងការស្រាវជ្រាវឯកសារ និងទិន្នន័យនានាដែលពាក់ព័ន្ធនឹងប្រធានបទខាងលើនេះ។ និងព្រមទាំងអរគុណយ៉ាងខ្លាំងបំផុត ចំពោះសិស្សសារការី ជំនាន់ទី២ បង **ម៉ៃ គីរត្ន** និង បង **ចំរើន** ដែលបានចូលរួមជាគំនិត និងបានផ្ដល់ជាមតិយោបល់ក្នុងសារណានេះផងដែរ ។

ជាចុងបញ្ចប់ យើងខ្ញុំសុំបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមជួយតាមថែរក្សាលោកទាំងអស់ឱ្យជួបប្រទះតែសេចក្ដីសុខ សុខភាពល្អ អាយុយឺនយូរ ដើម្បីបន្តដឹកនាំ និងផ្ដល់ចំណេះដឹងដល់កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយៗទៀត។

# អារម្ភកថា

យើងខ្ញុំទាំងពីរនាក់ គឺជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តឆ្នាំទី៤ ជំនាន់ទី ១៩ ដែលបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ចាប់តាំងពីឆ្នាំ២០១៥ រហូតដល់ឆ្នាំ ២០១៩។ បន្ទាប់ពីបានសិក្សាអស់រយៈពេល ៤ ឆ្នាំកន្លងមកនេះយើងបានទទួលនូវចំណេះដឹងជាច្រើន ពីសាស្រ្តាចារ្យទាំងឡាយ ដែលបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ដល់យើងខ្ញុំ ។ ហេតុដូច្នេះហើយ ដើម្បីធ្វើការវាយតម្លៃ និងវាស់ស្ទង់ទៅលើចំណេះដឹងរបស់ពួកយើងខ្ញុំដែលបានសិក្សាកន្លងមកក្នុងរយៈពេល ៤ឆ្នាំមកនេះ យើងខ្ញុំសូមលើកយកនូវប្រធានបទមួយដែលមានចំណងជើងថា "**តួនាទីសារការីក្នុងលិខិតមតកសាសន៍**" មកធ្វើការសិក្សាស្រាវជ្រាវដើម្បីធ្វើជាសារណាក្នុងការបញ្ចប់ការសិក្សា ។

មូលហេតុដែលយើងខ្ញុំសម្រេចចិត្ត លើកយកប្រធានបទនេះមកសរសេរសារណា គឺដើម្បីឲ្យមិត្តនិស្សិត និងមិត្តអ្នកអានដែលមានបំណងធ្វើការស្វែងយល់អំពីមុខងារសារការី ដែលទាក់ទងនឹងតួនាទីរបស់សារការីក្នុងលិខិតមតសាសន៍នេះ ដោយសារតែសារការីមានការចាប់អារម្មណ៍ក្នុងរយៈពេលក្រោយមកនេះ ។ តាមរយៈស្នាដៃនៃសារណារបស់ពួកខ្ញុំនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាអត្ថបទសារណាមួយនេះនឹងចូលរួមជាពិសេស ក្នុងការផ្សព្វផ្សាយ និងជាជំនួយដល់ស្មារតីផ្នែកច្បាប់ និងសម្រាប់បុគ្គលទូទៅមិនចំពោះតែអ្នកច្បាប់ ជាពិសេសសម្រាប់ សិស្ស និស្សិតណា ចង់ដឹងនិងចង់សិក្សាខាងវិជ្ជាជីវសារការីជាដើម ។

ដោយសារតែពេលវេលាក្នុងការសិក្សាស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សាមានរយៈពេលខ្លី ហើយម្យ៉ាងវិញទៀត ដោយសារតែចំណេះដឹងពួកយើងខ្ញុំនូវមានកម្រិត យើងខ្ញុំជឿជាក់ថា កំហុសដែលកើតមានឡើងដោយអចេតនាមួយចំនួន ដែលក្នុងនោះមានដូចជា កំហុសអក្ខរាវិរុទ្ធ ខ្លឹមសារអត្ថន័យ និងភាពខ្វះចន្លោះមិនគ្រប់ជ្រុងជ្រោយតាមខ្លឹមសារច្បាប់នឹងកើតមានក្នុងសារណានេះ ជាក់ជាពុំខាន ។ យើងខ្ញុំរីករាយទទួលនូវមតិរិះគន់ក្នុងន័យស្ថាប័នា ដើម្បីកែលំអនូវកំហុសឆ្គងពីសំណាក់ លោក លោកស្រីសាស្រ្តាចារ្យ ក៏ដូចជា មិត្តនិស្សិតទាំងឡាយ ដើម្បីបំពេញនូវរាល់កំហុសឆ្គង និងចំណុចខ្វះខាតទាំងឡាយដោយក្តីសោមនស្សរីករាយ ដោយមេត្រីភាពព្រមទាំង សូមអរគុណ និង អរព្រះគុណ ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**តួនាទីសារការីក្នុងការតាក់តែងមតកសាសន៍**

**១.១. ការតាក់តែងលិខិតមតកសាសន៍** ........ ៣

១.១.១.មតកសាសន៍ជាលិខិយថាភូត ........ ៣

១.១.១.១. ការប្រឹក្សាយោបល់ ........ ៤

១.១.១.២.ការតាក់តែង ........ ៤

១.១.១.៣. ការចុះហត្ថលេខារបស់ម្ចាស់បណ្តាំ ........ ៥

១.១.១.៤. ការចុះហត្ថលេខារបស់សាក្សី ........ ៥

១.១.១.៥. ការចុះហត្ថលេខារបស់សារការី ........ ៦

១.១.២.មតកសាសន៍ជាលិខិតសម្ងាត់ ........ ៦

១.១.២.១. ការទទួលយកបណ្តាំរបស់សារការី ........ ៧

១.១.២.២. ការធ្វើសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ ........ ៧

១.១.២.៣. ការចូលរួមពីសាក្សី ........ ៧

១.១.២.២. ការចុះហត្ថលេខាលើលិខិតដោយសារការី ........ ៨

១.១.៣.មតកសាសន៍ជាលិខិតឯកជន ........ ៨

**១.២. អានុភាពនៃការតាក់តែង** ........ ៩

១.២.១. អានុភាពចំពោះលិខិតមតកសាសន៍ ........ ៩

១.២.១.១. ការផ្តល់យថាភាព ........ ៩

១.២.១.២. មានការគាំពារពីច្បាប់ ........ ៩

១.២.២. ការកំណត់តម្លៃសេវា ........ ១០

១.២.២.១. តាមការព្រមព្រៀង ........ ១០

១.២.២.២. តាមទំហំមតកសាសន៍ ........ ១០

**១.៣. ការទទួលខុសត្រូវចំពោះលិខិតរបស់សារការីដែលបានតាក់តែង** ........................ ១១
១.៣.១. ការរក្សាការសម្ងាត់ ........................ ១១
១.៣.២. ព្យសនកម្ម ........................ ១២

**ជំពូកទី២**

**តួនាទីសារការីក្នុងការតម្កល់មតកសាសន៍**

**២.១ ការតម្កល់ និងការរក្សាទុកលិខិតមតកសាសន៍** ........................ ១៣
២.១.១ ការតម្កល់ ........................ ១៣
២.១.១ ការរក្សាទុក ........................ ១៤
**២.២ វិធីសាស្ត្រ និងការគ្រប់គ្រងឯកសារក្នុងការតម្កល់** ........................ ១៤
២.២.១. វិធីសាស្ត្រក្នុងការតម្កល់ ........................ ១៥
២.២.២. ការគ្រប់គ្រងឯកសារ ........................ ១៥
**២.៣ ការប្រគល់ត្រឡប់** ........................ ១៧
២.៣.១ ការចេញសេចក្តីចម្លង ........................ ១៧
៣.២.២ ការរៀបចំបថតចម្លង ........................ ១៧
**២.៤ ការកំណត់តម្លៃសេវារក្សាទុក** ........................ ១៨
២.៤.១ តម្លៃតាមការព្រមព្រៀងក្នុងការរក្សាទុក ........................ ១៨
២.៤.២ តម្លៃតាមទំហំមតកសាសន៍ក្នុងការព្រមព្រៀង ........................ ១៩

**ជំពូកទី៣**

**តួនាទីសារការីក្នុងការប្រតិបត្តិមតកសាសន៍**

**៣.១. ការចាប់ផ្តើមតួនាទីជាអ្នកប្រតិបត្តិមតកសាសន៍** ........................ ២០
៣.១.១. ការចាប់ផ្តើមសន្តតិកម្ម និងការយល់ព្រមកាន់កាប់មុខងារជាអ្នកប្រតិបត្តិ ........................ ២០
៣.១.១.១. ការចាប់ផ្តើមសន្តតិកម្ម ........................ ២០
៣.១.១.២. ការយល់ព្រមកាន់កាប់មុខងារជាអ្នកប្រតិបត្តិ ........................ ២១
៣.១.២. ការបើក និងការពិនិត្យបញ្ជាក់មតកសាសសន៍ ........................ ២១
៣.១.២.១. ភាពចាំបាច់នៃការបើក និងការពិនិត្យបញ្ជាក់ ........................ ២១

៣.១.២.២. ភាពចាំបាច់នៃហេតុដែលត្រូវគោរពមុន ........ ២២
៣.១.២.៣. លិខិតមតកសាសន៍ទទួលការពិនិត្យបញ្ជាក់ ........ ២៣
**៣.២. តួនាទីក្នុងការប្រតិបត្តិមតកសាសន៍** ........ ២៣
៣.២.១. ការធ្វើបញ្ជីសារពើភ័ណ្ឌ ........ ២៣
៣.២.២. ការគ្រប់គ្រងមតិក ........ ២៤
៣.២.៣. ការប្រតិបត្តិតាមខ្លឹមសារនៃមតកសាសន៍ ........ ២៥
៣.២.៤. ការជ្រើសតាំងបន្ត ........ ២៥
៣.២.៥. សហប្រតិបត្តិ ........ ២៦
**៣.៣. សោហ៊ុយអ្នកប្រតិបត្តិ** ........ ២៦
៣.៣.១. កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ ........ ២៦
១.២.៣ សោហ៊ុយផ្សេងទៀតក្រៅពីកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ ........ ២៨
**៣.៤. ការបញ្ចប់តួនាទីក្នុងការប្រតិបត្តិមតកសាសន៍** ........ ២៨
៣.៣.១. ការអនុវត្តចប់ ........ ២៨
៣.៣.២. ការលាឈប់ ........ ២៩
៣.៣.៣. ការបញ្ឈប់ ........ ២៩
៣.៣.៤. អានុភាពនៃការប្រតិបត្តិមតកសាសន៍ ........ ២៩
**សេចក្ដីសន្និដ្ឋាន** ........ ៣១
**អនុសាសន៍** ........ ៣៣
**ឯកសារយោង**
**ឧបសម្ពន្ធ**

# សេចក្តីផ្តើម

សារការី ជាវិជ្ជាជីវៈសេរីមួយដែលបានចាប់កំណើតឡើង និងបានកកើតសារជាថ្មីម្តងទៀត នៅក្នុងប្រទេសកម្ពុជាយើងក្នុងនីតិរដ្ឋថ្មីនេះ ហើយក្រោយពីវិជ្ជាជីវៈបានបាត់បង់ទៅអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ មុខងារសារការីត្រូវបានប្រសូតឡើងជាលើកដំបូងក្នុងឆ្នាំ១៩៥៤ តាមរយៈព្រះរាជក្រមលេខ ៩១០ ន.ស ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ១៩៥៤ ។ ប៉ុន្តែព្រះរាជក្រមនេះត្រូវបានផ្អាកក្នុងយុគ្គសម័យរបបខ្មែរក្រហមដោយសារតែមាននូវវិបត្តសង្គ្រាម ប៉ុន្តែ វិជ្ជាជីវៈសារការីត្រូវបានបង្កើតឡើង តាមរយៈក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ដែលក្នុងសារណានេះខ្ញុំសូមហៅកាត់ថា ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។ សារការីក្នុងនាពេលបច្ចុប្បន្នជាវិជ្ជាជីវៈដែលកំពុងមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ មេធាវី អ្នកច្បាប់ ប្រជាជន ជាពិសេសសិស្សនិស្សិតផ្នែកច្បាប់តែម្តង ។

យោងទៅតាមមាត្រា ១ នៃព្រះរាជក្រមលេខ៩១០ ន.ស ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ១៩៥៤ ដែលបានបញ្ញត្តិថា សារការី គឺជាមន្ត្រីសារធារណៈដែលតាំងឡើងតាមរយៈព្រះរាជក្រឹត្យនៃរាជរដ្ឋាភិបាល ហើយតាមរយៈព្រះរាជក្រឹត្យនេះយើងអាចនិយាយជារួមបានថា សារការីមានសមត្ថកិច្ចក្នុងការធ្វើលិខិតយថាភាព បញ្ជាក់ពីភាពត្រឹមត្រូវនៃលិខិត តម្កល់ រក្សទុក ចេញសេចក្តីចម្លងទាំងឡាយឲ្យទទួលបានយថាភាព និងបំពេញមុខងាររបស់ខ្លួនក្នុងការផ្តល់ចារឹកលក្ខណៈទៅតាមផ្លូវច្បាប់ដល់លិខិត ឬកិច្ចសន្យាទាំងឡាយដែលបានកំណត់ដោយច្បាប់ ។ ដោយឡែកបើយើងយោងទៅតាមអត្ថន័យនៃសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។

សារការីគឺជាវិជ្ជាជីវៈច្បាប់ ដែលមានតួនាទីយ៉ាងសំខាន់កក្នុងការតាក់តែងលិខិតយថាភូតបញ្ជាក់យថាភាពលើលិខិត និងតម្កល់លិខិតនានាដែលក្នុងពេលនេះក៏រួមបញ្ចូលផងដែរនូវលិខិតមតកសាសន៍ ។

ដោយសារតែមិនយល់ដឹងអំពីតួនាទីសារការី និងមិនយល់ពីការអនុវត្តរបស់សារការី ទើបនៅពេលដែលធ្វើមតកសាសន៍ម្តងៗ គេឃើញមានការប្រើប្រាស់សេវាមេធាវីក្នុងការតាក់តែង។ ពោលគឺមិនសូវឃើញប្រើប្រាស់សេវាសារការីនោះទេ ។

ដោយក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទ "*តួនាទីសារការីក្នុងមតកសាសន៍* " យើងខ្ញុំចង់បង្ហាញឲ្យបានច្បាស់អំពី កិច្ចការតាក់តែង ការតម្កល់ និងការប្រតិបត្តិមតកសាសន៍ ដើម្បីជាការចូលរួមចំណែកបង្កើតនូវចំនេះដឹងទាំងយើងខ្ញុំផ្ទាល់ ក៏ដូចជាចង់ចែករំលែកសិស្សនិស្សិតជំនាន់ក្រោយៗទៀត ។

សារណានេះត្រូវធ្វើការបានបែងចែកជាបីជំពូកដូចខាងក្រោម៖

ជំពូកទី ១៖ តួនាទីសារការីក្នុងការតាក់តែងមតកសាសន៍

ជំពូកទី ២៖ តួនាទីសារការីក្នុងការតម្កល់មតកសាសន៍

ជំពូកទី ៣៖ តួនាទីសារការក្នុងការប្រតិបត្តិមតកសាសន៍

# ជំពូកទី១

# តួនាទីសារការីក្នុងការតាក់តែងមតកសាសន៍

ដោយយោងទៅតាមសន្ទានុក្រមចំណុច១១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់ និងចែងថា *"មតកសាសន៍ គឺជាលិខិតបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលបានកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព"* ។ មតកសាសន៍ គឺជាលិខិតបណ្តាំដែលមតកជនកាលនៅរស់បានធ្វើដើម្បីកំណត់ចំណែកមតិក ឬវិធីបែងចែកមតិកទៅអោយសន្តតិជន ឬ អច្ច័យលាភី និងកំណត់អំពីបុគ្គលដែលត្រូវប្រតិបត្តិមតកសាសន៍។

នៅក្នុងជំពូកទី១ ការបកស្រាយ ពីតួនាទីសារការីក្នុងការតាក់តែងមតកសាសន៍ត្រូវបានបែងចែងជា ( ពីរ ) ចំណុចធំៗគឺៈ ការតាក់តែងលិខិតមតកសាសន៍ (១.១ ) អានុភាពនៃការតាក់តែង (១.២) ។

## ១.១. ការតាក់តែងលិខិតមតកសាសន៍

ការតាក់តែងលិខិតស្នាម និងការបញ្ជាក់ពីភាពត្រឹមត្រូវនៃលិខិតរួមទាំងមតកសាសន៍ផងនោះ គឺជាតួនាទីយ៉ាងសំខាន់របស់សារការី។ ដើម្បីឲ្យមានសុពលភាព មតកសាសន៍ត្រូវធ្វើឡើងដោយគោរពទៅតាមទម្រង់ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។

ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់ និងបែងចែកអំពីទម្រង់ជាទូទៅនៃមតកសាសន៍ ជាបី ប្រភេទ គឺ មតកសាសាន៍ជាលិខិតយថាភូត (១.១.១) មតកសាសសន៍ជាលិខិតសម្ងាត់ (១.១.២) និងមតកសាសន៍ជាលិខិតឯកជន (១.១.៣) ។

### ១.១.១.មតកសាសន៍ជាលិខិយថាភូត

តាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា ១១៧៣ មតកសាសន៍ជាលិខិតយថាភូត គឺជាមតក-សាសន៍ដែលតាក់តែងឡើងដោយសារការីបន្ទាប់ពីមានការប្រាប់ដោយផ្ទាល់មាត់ពីសំណាក់ម្ចាស់បណ្តាំ ដោយមានការចូលរួមពីសាក្សី តាមការកំណត់តាមទម្រង់ដែលមានដូចខាងក្រោមៈ

- ត្រូវមានវត្តមានសាក្សីយ៉ាងតិច ២នាក់ ។
- ម្ចាស់បណ្តាំត្រូវប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ចំពោះសារការី។
- សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្តាំ និងសាក្សីស្តាប់ ។

- បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សីបានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខអក្សរនោះត្រឹមត្រូវ ហើយជននីមួយៗនោះត្រូវចុះហត្ថលេខា ដើម្បីបញ្ជាក់អំពីឈ្មោះ អាយុ និងលំនៅឋាន និង
- ជាចុងក្រោយ សារការីត្រូវសរសេរថ្ងៃ ខែ ឆ្នាំ ហើយនឹងត្រូវចុះហត្ថលេខា។

### ១.១.១.១. ការប្រឹក្សាយោបល់

ការប្រឹក្សាយោបល់ គឺជាការប្រាប់ពីទម្រង់ផ្លូវច្បាប់ដោយសារការីទៅម្ចាស់បណ្តាំនៅក្នុងការតាក់តែងមតកសាសន៍ដើម្បីកុំឲ្យមានការបំពានទម្រង់ច្បាប់ណាមួយ។ ហើយការប្រឹក្សាយោបល់នោះទៀតសោត សារការីត្រូវប្រាប់អំពីរបៀបនៃការបែងចែកទ្រព្យរបស់ម្ចាស់បណ្តាំទៅសន្តតិជន និងអច្ច័យលាភីឲ្យបានច្បាស់លាស់ ដើម្បីកុំឲ្យមានការបំពានភាគបម្រុង ដែលជាមូលហេតុនាំឲ្យមានវិការៈនៃមតកសាសន៍។ សារការីត្រូវសិក្សាអំពីទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ម្ចាស់បណ្តាំមុនធ្វើការតាក់តែងមតកសាសន៍។

សារការី ជាការចាំបាច់ត្រូវតែជូនដំណឹងដល់ភាគីទាំងអស់អំពីធាតុសំខាន់ៗមួយចំនួនដែលចាំបាច់ដែលនឹងត្រូវធ្វើនៅក្នុងលិខត ដែលជនានុជនមានបំណងនឹងធ្វើនោះ ចំពោះមុខខ្លួន ។ ការប្រឹក្សារបស់សារការី គឺជាកាតព្វកិច្ចដែលត្រូវផ្តល់ឲ្យជនានុជននូវឱវាទ ឬការប្រឹក្សាយោបល់ដែលមានលក្ខណៈច្បាស់លាស់ ដោយគិតគូរពីផលប្រយោជន៍ដែលមានជូនដល់ជនានុជនទាំងអស់ដែលមាន ។ ករណីយកិច្ចជាដើមរបស់សារការី គឺត្រូវបំភ្លឺឲ្យដំណឹង និងទូន្មានគូសញ្ញាអំពីលិខិតដែលអ្នកនេះបានធ្វើ ឬមានបំណងចង់ធ្វើ ហើយដោយខ្លួនជាមន្ត្រីសាធារណៈត្រូវពិនិត្យឲ្យដឹងថា សេចក្តីកំណត់ចុះក្នុងលិខិតទាំងនោះត្រឹមត្រូវតាមការពិត។[1]

ក្នុងការអនុវត្តជាក់ស្តែងការតាក់តែងលិខិតគតិយុត្ត ឬ លិខិតយថាភូតផ្សេងៗ រួមទាំងមតកសាសន៍ជាលិខិតយថាភូតផងដែរ សារការីត្រូវធ្វើការប្រឹក្សាយោបល់ដល់ជនានុជន អំពីលិខិតស្នាមដែលបានស្នើសុំអោយធ្វើ សារការីមិនត្រឹមតែពន្យល់អំពីផលប្រយោជន៍ជូនដល់ជនានុជននោះទេ សារការីត្រូវពន្យល់អំពីផលប៉ះពាល់ រួមទាំងបញ្ហាផ្សេងៗដែលអាចទទួលយកបាន ឬកើតទៅថ្ងៃខាងមុខ ក្នុងការធ្វើមតកសាសន៍ ដើម្បីជៀសវាងការដែលមានបញ្ហាទៅពេលក្រោយ ដែលនឹងនាំអោយមានវិវាទ និងការខូចខាតផ្សេងៗដែលអាចកើតឡើងដោយការភាន់ច្រលំ ការធ្វេសប្រហែសក្នុងការតាក់តែង។

### ១.១.១.២.ការតាក់តែង

បើយើងក្រលែកទៅមើលបញ្ញត្តិស្តីពីមតកសាសន៍ មានបញ្ញត្តិជាច្រើនបាននិយាយពីទម្រង់នៃលិខិតមតកសាសន៍។ ប៉ុន្តែសូមលើឡើងនៅបញ្ញត្តិមួយចំនួនដែលពាក់ព័ន្ធសារការីមកនិយាយមតកសាសន៍ជាលិខិតយថាភូត គឺជាមតកសាសន៍ដែលតាក់តែងឡើងដោយសារការីផ្ទាល់ហើយ

[1] មាត្រា ១ កថាខណ្ឌ២ ចំណុច២ ព្រះរាជក្រម លេខ៩១០ ន.ស

ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះសារការីដោយម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ចំពោះសារការី ហើយសារការីត្រូវសរសេរនូវអត្ថបទនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះជាលាយលក្ខណ៍អក្សរហើយត្រូវសូត្រឲ្យម្ចាស់បណ្តាំ និងសាក្សីពីរនាក់ស្តាប់ នៅពេលដែលសារការីតាក់តែងមតកសាសន៍ជាលិខិតយថាភូតសារការីត្រូវគិតដល់ភាគបម្រុង ទ្រព្យសម្បត្តិសន្តតិជន ការកំណត់នូវចំណែក និងវិធីនៃការបែងចែកមតិក។ សារការីត្រូវសរសេរផងដែរនូវអច្ច័យទានទៅសន្តតិជន ឬតតិយជន ហើយព្រមទាំងកំណត់អភ័ព្វបុគ្គលនៃសន្តតិកម្ម មានការយល់ព្រមទទួល និងបោះបង់សន្តតិកម្ម ក្រៅពីនេះអាចជាការផ្តាច់មតិកប្រសិនបើមាន។

បន្ថែមទៀត សារការីក៏ត្រូវកំណត់អំពីបុគ្គលជាអ្នកទទួលបន្ទុកប្រតិបត្តិមតកសាសន៍ផងដែរប្រសិនបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈ។

### ១.១.១.៣. ការចុះហត្ថលេខារបស់ម្ចាស់បណ្តាំ

ក្រោយពីបានតាក់តែងរួចហើយ សារការីត្រូវអានមតកសាសន៍នោះចំពោះម្ចាស់បណ្តាំ និងសាក្សីចំនួនពីររូប។ ក្រោយពីម្ចាស់បណ្តាំទទួលស្គាល់ថា មតកសាសន៍ដែលសារការីបានតាក់តែងមានភាពត្រឹមត្រូវហើយម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើមតកសាសន៍។

ការចុះហត្ថលេខារបស់ម្ចាស់បណ្តាំ គឺជាលក្ខខណ្ឌចាំបាច់ក្នុងការដើម្បីបញ្ជាក់ពីភាពពិតប្រាកដនៃភាពត្រឹមត្រូវនៃមតកសាសន៍ បន្ទាប់ពីម្ចាស់បណ្តាំបានទទួលស្គាល់ថាកំណត់ជាលាយ-ល័ក្ខណ៍អក្សរនោះត្រឹមត្រូវ។ ជាគោលបំណងនៃហត្ថលេខាគឺដើម្បីផ្តល់សច្ចានុមតិលើភាពត្រឹមត្រូវនៃឈ្មោះ អាយុ ភេទ និងលំនៅឋាន រួមទាំងខ្លឹមសារនៃមតកសាសន៍ដែលត្រូវបានតាក់តែងដោយសារការីតាមរយៈការប្រាប់ផ្ទាល់មាត់ពីម្ចាស់បណ្តាំ ។ ហត្ថលេខានេះពុំអាចត្រូវបានជំនួសដោយស្នាមម្រាមដៃឡើយ ។ សារការីត្រូវពិនិត្យមើលលើការចុះហត្ថលេខារបស់ម្ចាស់បណ្តាំ នៅចំពោះមុខខ្លួនឲ្យបានត្រឹមត្រូវ។

### ១.១.១.៤. ការចុះហត្ថលេខារបស់សាក្សី

សាក្សី គឺជា ស្មរ ,បន្ទាល់ , បានដឹង បានលឺ បានឃើញ [2]។ ដោយសារសាក្សីគឺជាបុគ្គលដែលសំខាន់នៅក្នុងការដឹងលឺ និងបានចូលរួមក្នុងការតាក់តែងលិខិតមតកសាសន៍ បន្ទាប់ពីសាក្សីបានទទួលស្គាល់ថាមតកសាសន៍ដែលសារការីបានតាក់តែងពិតជាត្រឹមត្រូវ សាក្សីត្រូវសរសេរឈ្មោះ អាយុ ទីលំនៅ និងចុងក្រោយ សាក្សីត្រូវធ្វើការចុះហត្ថលេខាលើមតកសាសន៍។

ចំពោះសាក្សីដែលនឹងចុះហត្ថលេខាលើមតកសាសន៍ សារការីត្រូវពិនិត្យលើលក្ខណៈសម្បត្តិនៃបុគ្គលដែលនឹងធ្វើជាសាក្សី ដើម្បីឲ្យមានសភាពប្រាកដប្រជាថា បុគ្គលនោះមិនមែនជាសាក្សីដូចខាងក្រោម ៖

[2] យោងតាមវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត

- អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា ។
- ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និង ញាតិលោហិតខ្សែផ្ទាល់ របស់ជនទាំងនោះ។
- បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតសម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និង និយោជិត របស់សារការីនោះ។[3]

**១.១.១.៥. ការចុះហត្ថលេខារបស់សារការី**

ហត្ថលេខា គឺជាការសរសេរឈ្មោះខ្លួនដោយដៃខ្លួនឯង តាមចំណាំដែលធ្លាប់តែសរសេររៀងមកយ៉ាងណាក៏ឲ្យទៅជាយ៉ាងនេះ[4]។ មុននឹងសារការីចុះហត្ថលេខា លើលិខិតមតកសាសាន៍ សារការីត្រូវពិនិត្យមើលលើខ្លឹមសារនៃមតកសាសន៍ និងបានបញ្ជាក់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវ និងមានភាពច្បាស់លាស់។ បន្ទាប់មកសារការីត្រូវពិនិត្យទៅលើសាក្សីដែលបានចុះហត្ថលេខា មានសរសេរ ឈ្មោះ ភេទ អាយុ ត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី ។

ត្រា គឺជាប្រដាប់មានស្នាមចម្លាក់ជាគ្រឿងសម្គាល់សម្រាប់សម្គាល់លើសំបុត្រ, ចុតហ្មាយដីកា, បញ្ជី, សំបុត្រសន្យាផ្សេងៗតាមមុខងារ មុខក្រសួងបោះត្រា[5]។ ហើយត្រារបស់សារការីមានពីរប្រភេទ៖ ត្រាមន្ទីររបស់សារការី និង ត្រាឈ្មោះរបស់សារការីដែលបានបោះលើលិខិតនោះ ។

ក្នុងករណីដែលសារការី ត្រូវបានចុះហត្ថលេខា សារការីគ្រាន់តែសរសេរនាមត្រកូល និង នាមខ្លួន និង ផ្តិមមេដៃជាការគ្រប់គ្រាន់ហើយ[6]។

**១.១.២.មតកសាសន៍ជាលិខិតសម្ងាត់**

មតកសាសន៍ជាលិខិតសម្ងាត់ គឺជាមតកសាសន៍ដែលតាក់តែងដោយ ម្ចាស់បណ្តាំខ្លួនឯង ឬ អ្នកដទៃដែលមិនមែនជាសារការី ហើយដាក់ក្នុងស្រោមសំបុត្របិទជិត បន្ទាប់មកយកប្រគល់ជូនសារការីដើម្បីឲ្យសារការីទទួលដឹងលឺ ដោយមានការចូលរួមពីសាក្សីពីរនាក់ផងដែរ។ មតកសាសន៍ជាលិខិតសម្ងាត់ គឺជាមតកសាសន៍មួយដែលធ្វើឡើងក្នុងគោលដៅរក្សាភាពសម្ងាត់ចំពោះខ្លឹមសារនៃមតកសាសន៍ទាំងស្រុងដើម្បីការពារការបង្ហាញឆន្ទៈរបស់ម្ចាស់បណ្តាំហើយព្រមទាំង ដើម្បីកុំឲ្យមានការច្រណែនគ្នារវាងសន្តតិជន។

[3] មាត្រា ១១៧២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[4] យោងតាមវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត
[5] យោងតាមវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត
[6] មាត្រា ១១៨០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

**១.១.២.១. ការទទួលយកបណ្តាំរបស់សារការី**

នៅពេលសារការីទទួលយកបណ្តាំ សារការីមិនត្រូវពិនិត្យមើលអត្ថន័យនៃបណ្តាំឡើយ។ ផ្ទុយទៅវិញ សារការីត្រូវពិនិត្យមើលអំពីការបិទជិតស្រោមសំបុត្រ នឹងការចុះហត្ថលេខារបស់ម្ចាស់បណ្តាំ ឬ ការធ្វើសញ្ញាសម្គាល់ ឬមធ្យោបាយផ្សេងៗដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតដែលបានដាក់លិខិតបណ្តាំ[7]។

ការធ្វើបែបនេះដើម្បីធានាភាពសម្ងាត់នៃខ្លឹមសារមតកសាសន៍ និងគោរពទៅតាមទម្រង់នៃមតកសាសន៍ជាលិខិតសម្ងាត់ដែលសារការីទទួលយកបណ្តាំមករក្សាទុកនៅចំពោះមុខខ្លួន ។

**១.១.២.២. ការធ្វើសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ**

ម្ចាស់បណ្តាំត្រូវធ្វើសេចក្តីថ្លែងការណ៍ដោយបង្ហាញឆន្ទៈចំពោះសារការី ដើម្បីបញ្ជាក់ថាលិខិតដែលនៅក្នុងស្រោមសំបុត្របិទជិត គឺជាមតកសាសន៍ និងអំពីការដែលខ្លួនបានសរសេរក្នុងបណ្តាំដោយផ្ទាល់ដៃ ប្រសិនបណ្តាំសរសេរដោយម្ចាស់បណ្តាំផ្ទាល់។ លើសពីនេះ ប្រសិនបើម្ចាស់បណ្តាំឲ្យអ្នកដទៃសរសេរជំនួស ម្ចាស់បណ្តាំត្រូវបញ្ជាក់អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរជំនួសម្ចាស់បណ្តាំ។[8]

បន្ទាប់ពីម្ចាស់បណ្តាំថ្លែងការណ៍ចំពោះខ្លួនដូចខាងលើ សារការីត្រូវអោយម្ចាស់បណ្តាំចុះហត្ថលេខាលើមតកសាសន៍ជាលិខិតសម្ងាត់នោះ ព្រមទាំងមានសាក្សីពីរនាក់ចូលរួម ដើម្បីបញ្ជាក់ថា មតកសាសន៍ជាលិខិតសម្ងាត់នោះពិតជាត្រឹមត្រូវ ។

**១.១.២.៣. ការចូលរួមពីសាក្សី**

ខុសពីមតកសាសន៍ជាលិខិតយថាភូត សាក្សីក្នុងរឿងមតកសាសន៍ជាលិខិតសម្ងាត់ពុំមានតួនាទីក្នុងការចងចាំខ្លឹមសារនៃលិខិតបណ្តាំ ដោយហេតុថាសាក្សីពុំបានអាន ឬ ស្តាប់អំពីខ្លឹមសារនៃបណ្តាំឡើយ ។ សាក្សីក្នុងមតកសាសន៍ជាលិខិតសម្ងាត់ គ្រាន់តែដើរតួរជាអ្នកដែលបានធានាថាម្ចាស់បណ្តាំពិតជាបានយកមតកសាសន៍ដាក់ក្នុងសំបុត្របិទជិត និងចុះហត្ថលេខាលើស្រោមសំបុត្រមតកសាសន៍តែប៉ុណ្ណោះ ។

ក្នុងនាមជាសារការី មានតួនាទីយ៉ាងសំខាន់ក្នុងការពិនិត្យលក្ខណៈសម្បត្តិរបស់សាក្សីដែលត្រូវចូលរួម។ ព្រោះថាកាលណាសាក្សីដែលចូលរួមជាបុគ្គលដែលត្រូវបានហាមឃាត់ មតកសាសន៍ដែលបានធ្វើនឹងត្រូវចាត់ទុកជាមោឃៈ។ បុគ្គលដែលមិនអាច ធ្វើជាសាក្សីក្នុងមតកសាសន៍ជា

[7] មាត្រា ១១៧៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ចំណុច ខ
[8] មាត្រា ១១៧៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ចំណុច គ

លិខិតសម្ងាត់ ក៏ដូចគ្នាទៅនឹងចំណុច ១.១.១.៤ ដែលបានរៀបរាប់អំពីសាក្សីក្នុងមតកសាសន៍ជាលិខិតយថាភូតផងដែរ។

**១.១.២.២. ការចុះហត្ថលេខាលើលិខិតដោយសារការី**

ដោយសារខ្លួនជាមន្ត្រីសាធារណៈ សារការីត្រូវបានប្រគល់នូវអំណាចជូនដោយច្បាប់តាមរយៈប្រតិភូកម្មហត្ថលេខា និងដើម្បីបញ្ជាក់នូវយថាភាពដល់លិខិតដែលទទួលធ្វើ និងសន្យាទទួលខុសត្រូវចំពោះភាពត្រឹមត្រូវតាមទម្រង់ច្បាប់ និងកាលបរិច្ឆេទនៃលិខិតដែលខ្លួនបានធ្វើ ឬបញ្ជាក់។

បន្ទាប់ពីសារការីបានទទួលយកបណ្តាំ និងបានពិនិត្យមើលលើបណ្តាំថាត្រឹមត្រូវទៅតាមល័ក្ខខណ្ឌ ដូចបានជម្រាបជូនខាងលើ សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លើលិខិត និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើស្រោមសំបុត្រដែលបិទជិត និងជាចុងក្រោយត្រូវចុះហត្ថលេខាលើស្រោមសំបុត្របិទជិតនោះ ជាមួយគ្នានឹងសាក្សី និងម្ចាស់បណ្តាំ[9]។

**១.១.៣.មតកសាសន៍ជាលិខិតឯកជន**

មតកសាសន៍ ជាលិខិតឯកជនជាទម្រង់មួយដែលមានល័ក្ខខ័ណ្ឌពុំសូវស្មុគស្មាញទេ ។ វាពុំតម្រូវអោយមានសាក្សីជាអាទិ៍ សារការី ឬជំនួយអ្វីផ្សេងៗ ដើម្បីធានាភាពត្រឹមត្រូវនៃលិខិតបណ្តាំនោះទេ។

ដើម្បីធ្វើមតកសាសន៍ជាលិខិតឯកជន ម្ចាស់បណ្តាំត្រូវសរសេរមតកសាសន៍ទាំងមូលព្រមទាំងចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ។ មតកសាសន៍ជាលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដ៍ទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនជាអង្គុលី-លេខ ជាអាទិ៍ នឹងត្រូវចាត់ជាមោឃៈ។[10] ហេតុនេះហើយបានជាតម្រូវឲ្យម្ចាស់បណ្តាំសរសេរខ្លឹមសារនៃមតកសាសន៍ និង ទាមទារឲ្យចុះហត្ថលេខា ជាអាទិ៍ ដោយសាមីខ្លួនផ្ទាល់ ។

នៅក្នុងលិខិតមតកសាសន៍ ជាលិខិតឯកជន សារការីពុំមានតួនាទី ក្នុងការតាក់តែង ការចុះហត្ថលេខា ការទទួលយកបណ្តាំ និងពុំមានការប្រថាប់ត្រានោះទេ ពោលគឺម្ចាស់បណ្តាំខ្លួនឯងផ្ទាល់ជាអ្នកតាក់តែង ហើយចុះហត្ថលេខាលើលិខិតមតកសាសន៍ ហើយរក្សាទុកដោយខ្លួនឯងដោយពុំមានសារការីចូលរួមនោះទេ។ ប៉ុន្តែសារការីអាចចូលរួមជាការប្រឹក្សាយោបល់ជូនម្ចាស់បណ្តាំបាន ។

[9] មាត្រា ១១៧៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ចំណុច ឃ

[10] មាត្រា ១១៧៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ កថាខណ្ឌទី ១

## ១.២. អានុភាពនៃការតាក់តែង

នៅពេលដែលសារការីបានធ្វើការតាក់តែងនូវមតកសាសន៍រួចរាល់ និងគោរពទៅតាមបញ្ញត្តិនៃច្បាប់ និងគោរពទៅតាមនីតិវិធី ព្រមទាំងបែបបទគតិយុត្តិនៃច្បាប់ នឹងនាំអោយលិខិតមតកសាសន៍នោះមានសុពលភាព ។

ដើម្បីមានភាពងាយយល់អំពីអានុភាពនៃការតាក់តែង គប្បីស្វែងយល់ពី អានុភាពចំពោះលិខិតមតកសាសន៍ (១.២.១) និងការកំណត់តម្លៃសេវា (១.២.២ ) ។

### ១.២.១. អានុភាពចំពោះលិខិតមតកសាសន៍

#### ១.២.១.១. ការផ្តល់យថាភាព

សារការី ជាមន្ត្រីដែលមានសមត្ថកិច្ចក្នុងការតាក់តែងលិខិតមតកសាសន៍ ហើយមតកសាសន៍ ដែលតាក់តែងឡើងតាមរយៈសារការី ត្រូវបានហៅថា មតកសាសន៍ជាលិខិតយថាភូត។ សារការី ផ្តល់យថាភាព ទៅលើលិខិតមតកសាសន៍ជាលិខិតយថាភូតភាព តាមរយៈការផ្ទៀងផ្ទាត់ខ្លឹមសារនៃមតកសាសន៍ ពិនិត្យអត្តសញ្ញាណរបស់ម្ចាស់បណ្តាំ សាក្សីទាំងពីរនាក់ បញ្ជាក់ថាមានវត្តមានពិតប្រាកដមែន និងសារការីត្រូវពិគ្រោះយោបល់ផ្នែកច្បាប់ បន្ទាប់មកសារការី ត្រូវចុះហត្ថលេខា និងធ្វើការបោះត្រា ដើម្បីបញ្ជាក់យថាភូតភាពលើលិខិតមតកសាសន៍។ បន្ទាប់ពីសារការីបានផ្តល់យថាភូតភាពលើមតកសាសន៍រួចរាល់ ហើយមតកសាសន៍នោះ និងត្រូវបានក្លាយទៅជាមតកសាសន៍ជាលិខិតយថាភូត។

#### ១.២.១.២. មានការគាំពារពីច្បាប់

មតកសាសន៍ដែលបានតាក់តែងឡើងដោយសារការី ជាមតកសាសន៍មួយត្រូវចាត់ទុកជាមតកសាសន៍ជាលិខិតយថាភូត ដោយសារសារការីជាមន្ត្រីដែលទទួលបានប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា ពីរដ្ឋាភិបាលក្នុងការតាក់តែងលិខិតមកតសាសន៍ត្រឹមត្រូវនិងស្របតាមទម្រង់ច្បាប់។ មតកសាសន៍ដែលបានតាក់តែងឡើងដោយសារការី ត្រូវបានការគាំពារពីច្បាប់យ៉ាងពេញទី នៅពេលដែលមតកសាសន៍គោរពទៅតាមបទដ្ឋានគតិយុត្ត ឬបញ្ញត្តិនៃច្បាប់ដែលបានកំណត់ និងបានចែងយ៉ាងច្បាស់លាស់ជាក់លាក់។

រាល់មតកសាសន៍ដែលតាក់តែងដោយសារការីត្រូវបានការគាំពារពីច្បាប់ ខុសគ្នាដាច់ស្រឡះពីមតកសាសន៍ជាលិខិតឯកជន ដោយសារតែមតកសាសន៍ជាលិខិតយថាភូត មានអានុភាព និងមានតម្លៃគតិយុត្តតាមផ្លូវច្បាប់ដែលត្រូវតែជឿ ឬនិយាយមួយបែបទៀតថា មតកសាសន៍ជាលិខិតយថាភូត គឺជាមតកសាសន៍ដែលត្រូវចាត់ទុកថា ត្រឹមត្រូវពិតប្រាកដ និង

ស្របតាមទម្រង់ច្បាប់។ លើកលែងតែមតកសាសន៍ជាលិខិតយថាភូតនោះជាមតកសាសសន៍ក្លែងក្លាយយ៉ាងពិតជាក់ស្តែង[11]។

### ១.២.២. ការកំណត់តម្លៃសេវា

តាមការអនុវត្តមុខងាររបស់មន្ទីរសារការីនៃព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានឃើញបទដ្ឋានគតិយុត្តណាមួយ កំណត់ពីតម្លៃសេវាដែលសារការីទទួលដើម្បីបម្រើដល់អតិថិជនក្នុងការធ្វើលិខិតមតកសាសន៍ជាលិខិតយថាភូតឡើយ។ ជាក់ស្តែងតម្លៃសេវាកម្មសារការី ត្រូវបានកំណត់ទៅតាមមូលដ្ឋានផ្សេងៗគ្នាពីសារការីម្នាក់ទៅសារការីម្នាក់ ដែលអាចកំណត់តាមការព្រមព្រៀង ឬតាមទំហំនៃការទទួលខុសត្រូវរបស់សារការី។

សេវាកម្មសារការីនៅមានតម្លៃខ្ពស់ បើប្រៀបធៀបទៅនឹងតម្លៃសេវាកម្មនៃវិជ្ជាជីវៈសេរីដ៏ទៃផ្សេងទៀត ដូចជាវិជ្ជាជីវៈមេធាវីជាដើម ដែលជាហេតុ កម្រឃើញអ្នកដែលមានជីវភាពធម្មតា ទៅប្រើប្រាស់សេវាសារការីធ្វើការតាក់តែងលិខិត និងធ្វើកិច្ចសន្យា ក៏ដូចជាមតកសាសន៍ផងដែរ។

#### ១.២.២.១. តាមការព្រមព្រៀង

ដោយសារតែមិនមានបទដ្ឋានគតិយុត្តិណាមួយ កំណត់អំពីតម្លៃសេវាសារការីក្នុងការតាក់តែងនូវលិខិតមតកសាសន៍ គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនត្រូវបានយកមកប្រើដើម្បីកំណត់តម្លៃសេវាកម្មរបស់សារការី។ គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន គឺសំដៅទៅដល់ការព្រមព្រៀងក្នុងការកំណត់តម្លៃសេវាកម្មរវាងសារការី និងអតិថិជនរបស់ខ្លួនដែលជាម្ចាស់បណ្តាំ។

ការព្រមព្រៀងខាងលើ តម្រូវឲ្យម្ចាស់បណ្តាំ និងសារការីយល់ព្រមដោយឆន្ទៈពិតប្រាកដដោយសេរី ក្នុងការទទួលយកតម្លៃ និងយល់ព្រមក្នុងការផ្តល់តម្លៃជូនសារការីដោយមិនមានការបង្ខិតបង្ខំពីនរណាម្នាក់ឡើយ។

#### ១.២.២.២. តាមទំហំមតកសាសន៍

សេវាតាមទំហំនៃមតកសាសន៍មកដល់ពេលនេះ ពុំទាន់មានបទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិ ឬប៉ារ៉ែនស្ថាប័នក្រសួងណាមួយកំណត់ឲ្យច្បាស់លាស់នៅឡើយទេ ។ ដោយយោងតាមគំរូតារាង

[11] មាត្រា ២០ កថាខណ្ឌទី៣ នៃសេចក្តីព្រាងច្បាប់ពីលក្ខន្តិកៈសារការី ឆ្នាំ២០១៧

តម្លៃប្រាក់កំរៃ ឬប្រាក់ឈ្នួលរបស់លោកមេធាវី សារការីប៉ែន សុនសម័យក្នុងការធ្វើលិខិត ឬ ធ្វើចារឹតសារការី ការបញ្ចាំ ចងការ ជួលលក់អចលនវត្ថុផ្សេងៗទៀត (គឺពុំមែនជាព្រះរាជក្រឹត្យ) ។[12]

| | |
|---|---|
| ពី០ដល់១០.០០០.០០០រៀល | ៣.៣៣% |
| ពី១០.០០០.០០០ដល់២០.០០០.០០០រៀល | ២.២% |
| ពី២០.០០០.០០០ដល់៥០.០០០.០០០រៀល | ១.១% |
| ពី៥០.០០០.០០០រៀលដល់៥០០.០០០.០០០រៀល | ០.៨% |
| ពី៥០០.០០០.០០០រៀលឡើងទៅ | ០.៥៥% |

## ១.៣. ការទទួលខុសត្រូវចំពោះលិខិតរបស់សារការីដែលបានតាក់តែង

តួនាទីរបស់សារការីក្នុងការប្រតិបត្តិការគតិយុត្តមួយ មិនមែនបញ្ចប់នៅពេលដែលខ្លួនបានផ្តល់យថាភាព បានចុះហត្ថលេខា និងប្រថាប់ត្រាលើលិខិតនោះប៉ុណ្ណោះទេ ប៉ុន្តែសារការីត្រូវបានចងភ្ជាប់នឹងការទទួលខុសត្រូវដែលអាចកើតចេញពីការតាក់តែងលិខិតនោះផងដែរ ។ ភ្ជាប់ជាមួយនិងសិទ្ធិដែលទទួលបានក្នុងការធ្វើកិច្ចការងារដែលបាននិយាយរៀបរាប់ខាងលើ ឬក៏ការរៀបរាប់ក្នុងផ្នែកផ្សេងៗខាងលើទាំងអស់នេះ សារការីតម្រូវឲ្យមានកាតព្វកិច្ច និងករណីកិច្ច ឬអាចនិយាយបានថា ក្រមសីលធម៌របស់វិជ្ជាជីវៈមួយនេះផងដែរ ដែលតម្រូវឲ្យមានជាចាំបាច់ ដែលមិនអាចខ្វះបាននោះ ៖

### ១.៣.១. ការរក្សាការសម្ងាត់

ការរក្សាការសម្ងាត់ ជាលក្ខខណ្ឌចាំបាច់របស់សារការី នៅពេលខ្លួនបានតាក់តែង និងទទួលមតកសាសន៍ជាលិខិតសម្ងាត់មករក្សាទុកនៅក្នុងមន្ទីររបស់ខ្លួន។ សារការីត្រូវតែរក្សាមតកសាសន៍ក៏ដូចជាខ្លឹមសារ នៃមតកសាសន៍ជាការសម្ងាត់បំផុត ដើម្បីកុំអោយមានការលេចលឺ នឹងបានដឹងនូវខ្លឹមសារនៃមតកសាសន៍ ដល់សន្តតិជន អច្ច័យលាភី ឬជនដែលពាក់ព័ន្ធផលប្រយោជន៍ វាជាហេតុធ្វើអោយប៉ះពាល់ដល់ឆន្ទៈរបស់មតកជន។ ការក្សាការសម្ងាត់របស់សារការីនៃមតកសាសន៍ជាកត្តាសំខាន់មួយ ដែលសារការីមិនត្រូវបង្កើតឲ្យមានព័ត៌មានបែកធ្លាយទៅខាងក្រៅ។ ដូច្នេះ សារការី នៅពេលដែលខ្លួនបានតាក់តែងមតកសាសន៍រួចរាល់ ឬទទួលមតកសាសន៍ជាលិខិតសម្ងាត់ពីមតកជនសារការីត្រូវតែយកមតកសាសន៍ និងធ្វើសេចក្តីថ្លែងការណ៍ប្រាប់ទៅម្ចាស់បណ្តាំថា ខ្លួននិងរក្សា

[12] អាំង អេងថុង វិជ្ជាជីវៈសារការីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១២

ខ្លឹមសាររបស់មតកសាសន៍នេះ មិនអោយសន្តតិជន អច្ច័យលាភី ឬជនដែលពាក់ព័ន្ធផលប្រយោជន៍បានដឹងពីខ្លឹមសារមតកសាសន៍ជាដាច់ខាត។

**១.៣.២. ព្យសនកម្ម**

ព្យសនកម្ម មានន័យថា ជាការខូចខាត ឬសេចក្តីវិនាស អន្តរាយ ដល់រូបរាងកាយក្តី ដល់សម្ភារៈក្តី ដល់ទឹកចិត្តក្តី ដែលបណ្តោយមកពីអំពើរបស់សារការី។ ដូចគ្នានេះផងដែរ ព្យសនកម្មដែលកើតឡើងដោយអំពើរបស់សារការីបណ្តាលមកពី ការធ្វេសប្រហែសខ្វះភាពប្រុងប្រយ័ត្ន មិនគោរពកាតព្វកិច្ចណាមួយ ក្នុងការបំពេញកិច្ចការងារនៃមុខងាររបស់ខ្លួនដែលធ្វើឲ្យខូចខាតដល់ផលប្រយោជន៍របស់មតកជនក្នុងការតាក់តែងលិខិតមតកសាសន៍។ ដែលកំហុសនោះ អាចជាកំហុសផ្នែកបច្ចេកទេស ឬអក្ខរាវិរុទ្ធ នៅក្នុងខ្លឹមសារមតកសាសន៍ដែលខ្លួនបានតាក់តែង។ ជាក់ស្តែងការធ្វើឲ្យខូចខាតប្រយោជន៍របស់មតកជន ដែលបណ្តាលមកពីការបំពេញមុខងាររបស់ខ្លួន ជាកាតព្វកិច្ចសារការីត្រូវជួសជុលព្យសនកម្មដល់មតកជន។ យោងតាមមាត្រា៥ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការបង្កើតមន្ទីរសារការីអង្គរ នៃព្រះរាជាណាចក្រ បានចែងថា មន្ទីរសារការី ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០៛ (ប្រាំមួយរយលាន) រៀល នៅធានាគារជាតិនៃកម្ពុជា សម្រាប់ការធានាទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

# ជំពូកទី២

# តួនាទីសារការីក្នុងការតម្កល់មតកសាសន៍

បន្ទាប់ពីសារការីបានគាត់តែងលិខិតមតកសាសន៍រួចរាល់ ជាគោលការណ៍សារការី ត្រូវតែមានកាតព្វកិច្ចយកលិខិមតកសាសន៍នោះ មកតម្កល់ទុកនៅមន្ទីររបស់ខ្លួន ហើយការតម្កល់ទុកត្រូវមានកាតព្វកិច្ចថែរក្សាឲ្យល្អប្រសើរ និងមានសណ្តាប់ធ្នាប់ល្អ ហើយព្រមទាំងរក្សាបាននូវភាពគង់វង្សល្អនិងមានសុវត្ថិភាពរហូតដល់ថេរវេលាកំណត់ណាមួយ។ ដើម្បីមានសភាពងាយស្រួលនិងឲ្យកាន់តែច្បាស់លាស់នូវតួនាទីរបស់សារការី ក្នុងការតម្កល់មតកសាសន៍នោះ ។ យើងគប្បីស្វែងយល់ពីអត្ថន័យ ការតម្កល់ និងការរក្សាទុកលិខិតមតកសាសន៍ (២.១) វិធីសាស្ត្រ និងការគ្រប់គ្រងឯកសារក្នុងការតម្កល់ (២.២) ការចេញសេក្តីចម្លងតាមការស្នើសុំ (២.៣) និងការកំណត់តម្លៃសេវារក្សាទុក (២.៤) ។ ជាចំណុចដែរត្រូវបកស្រាយជាបន្តបន្ទាប់ ។

## ២.១ ការតម្កល់ និងការរក្សាទុកលិខិតមតកសាសន៍

រហូតមកដល់បច្ចុប្បន្ន ពុំទាន់មានឃើញបទដ្ឋានគតិយុត្តិណាមួយចែងឲ្យច្បាស់ និងជាក់លាក់អំពីលក្ខខណ្ឌក្នុងតម្កល់ និងការរក្សាទុកលិខិតមតកសាសន៍នោះទេ។ ជាក់ស្តែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ក៏ពុំទាន់បានបញ្ញាត្តិឲ្យច្បាស់អពីការតម្កល់ និងការរក្សាទុកលិខិតមតកសាសន៍ ផងដែរ។ ប៉ុន្តែតាមការអនុវត្តមុខងារសារការីតាមមន្ទីរនីមួយៗ នៅពេលដែលសារ-ការីគាក់តែងមតកសាសន៍រួចរាល់ ហើយមតកជនបានប្រគល់លិខិតមតកសាសន៍ មកឲ្យសារការីដើម្បីតម្កល់ និងរក្សាទុកក្នុងមន្ទីរសារការី ត្រូវមានកាតព្វកិច្ចក្នុងការតម្កល់ ឬរក្សាទុកមតកសាសន៍នោះ ប្រកបទៅដោយសុវត្ថិភាព និងអាចធានាបានថា មតកសាសន៍ មិនមានការបាត់បង់ហើយអាចប្រតិបត្តិមតកសាសន៍បាន នៅពេលដែលមតកជនទទួលមរណភាព។

### ២.១.១ ការតម្កល់

តាមការអនុវត្តជាក់ស្តែងតាមមន្ទីរសារការីរបស់ប្រទេសកម្ពុជា នៅពេលដែលសារការីទទួលតម្កល់ពីម្ចាស់បណ្តាំ សារការីត្រូវចេញលិខិតបញ្ជាក់មួយច្បាប់ ជូនទៅម្ចាស់បណ្តាំ ដើម្បីទុកជាសក្ខីកម្មថាម្ចាស់បណ្តាំបានប្រគល់លិខិតមតកសាសន៍របស់ខ្លួនអោយទៅមន្ទីរសារការី ដើម្បីធ្វើការតម្កល់ទុកក្នុងមន្ទីរសារការី រហូតដល់ពេលត្រូវចាប់ផ្តើមប្រតិបត្តិមតកសាសន៍។ ការតម្កល់នោផងដែរ សារការីត្រូវប្រើប្រាស់វិធីសាស្ត្របែបណាក៏ដោយត្រូវតែតម្កល់មកតសាសន៍ ធានាបាននូវភាពគង់វង្ស និងធានាបាននៅសុវត្ថិភាពខ្លឹមសារមតកសាសន៍ ។ ហើយនៅពេលដែលមតកជន

ទទួលមរណភាពគាត់មានតួនាទីក្នុងការបើកនូវលិខិតបណ្តាំ និងធ្វើការបែកចែកទ្រព្យសម្បត្តិតាមខ្លឹមសារដែលមាននៅក្នុងលិខិតបណ្តាំ។ ហើយការតម្កល់ឯកសារនេះទៀតសោត សារការីមិនមែនបញ្ចប់នៅពេលដែលខ្លួនបានប្រតិបត្តិមតកសាសន៍រួចរាល់ទេ សារការីមានកាតព្វកិច្ចត្រូវតម្កល់លិខិតមតកសាសន៍នោះ រយៈពេល ៥០ឆ្នាំ ទៀត ទើបអាចយកលិខិតមតកសាសន៍ មកផ្សព្វផ្សាយជាសាធារណៈបាន[13]។

### ២.១.១ ការរក្សាទុក

ជាគោលការណ៍ការរក្សាទុកឯកសាររបស់សារការី ធ្វើយ៉ាងណាឲ្យឯកសារនោះ ធានាបាននូវភាពល្អ សុវត្ថិភាពបំផុត និងអាចធានាបានថាមិនមានការបាត់បង់។ តាមការអនុវត្តជាក់ស្តែងរបស់មន្ទីរសារការីក្នុងព្រះរាជាណាចក្រកម្ពុជា ពុំមានបទប្បញ្ញត្តិណាមួយកំណត់អំពីរបៀបនៃការរក្សាទុកឯកសារនោះទេ ភាគច្រើនការរក្សាមតកសាសន៍របស់មន្ទីរសារការីនីមួយៗ តែងតែមានយុត្តិសាស្ត្រ ក្នុងការរក្សាទុកហើយមតកសាសន៍ដែលខ្លួនបានតាក់តែង ឬមតកជនប្រគល់មតក-សាសន៍មកខ្លួនរក្សាទុកសារការីត្រូវតែមានវិធានការក្នុងការរក្សាទុកមតកសាសន៍ ទៅតាមរបៀបនិងបែបបទនៃការរក្សាទុកក្នុងមន្ទីរសារការីរបស់ខ្លួន។ របៀនិងបែបបទនៃការរក្សាទុកមតកសាសន៍របស់មន្ទីរសារការី នៅប្រទេសកម្ពុជា មានដូចខាងក្រោម:

- រក្សាទុកឲ្យបានគង់វង្ស
- រក្សាទុកកន្លែងដែលមានមានសុវត្ថិភាព
- រក្សាទុកឲ្យមានរបៀបរៀបរយ
- រក្សាទុកឲ្យមានសោភ័ណ្ឌភាព

## ២.២ វិធីសាស្ត្រ និងការគ្រប់គ្រងឯកសារក្នុងការតម្កល់

ជាគោលការណ៍តាមមន្ទីរសារការីនីមួយៗ តែងតែមានរបៀប និងយុត្តិសាស្ត្រក្នុងការគ្រប់គ្រងរាល់ឯកសារ និងលិខិតដែលខ្លួនបានតាក់តែង ដើម្បីរក្សាទុកលិខិតឬឯកសារនោះ ឲ្យបានគង់វង្សមិនមានការខូចខាត និងធានាបាននូវខ្លឹមសារនៃលិខិតមតកសាសន៍ រហូតដល់អំឡុងពេលត្រូវអនុវត្ត។

[13] មាត្រា ៩១ នៃច្បាប់ស្តីពីបណ្ណាសារកម្ពុជា

### ២.២.១. វិធីសាស្ត្រក្នុងការតម្កល់

មកទល់ពេលបច្ចុប្បន្ន មិនមានសេចក្តីណែនាំណាមួយអំពីវិធីសាស្ត្រក្នុងការតម្កល់ឯកសារនិយាយជារូប ឬ មតកសាសន៍ និយាយដោយឡែក របស់សារការីឡើយ។ មន្ទីសារការីខ្លួនឯងជាអ្នកជ្រើសរើសវិធីសាស្ត្រត្រឹមត្រូវណាមួយដើម្បីរក្សាសុវត្ថិភាព និងមានសភាពងាយស្រួលក្នុងការស្វែងរកនូវមតកសាសន៍។

វិធីសាស្ត្រនោះមានដូចជា៖

- ទុកនៅក្នុងឃ្លាំង
- ទុក នៅក្នុង Soft
- ទុកក្នុងទូកដែក
- ទុកដាក់តាមលំដាប់លំដោយ
- ទុកនៅក្នុងក្រូណូ
- ទុកក្នុងប្រអប់
- ទុកដាក់ជាការបង់លេខរៀង
- ទុកដាក់ជាប័ណ្ណពណ៌ក្នុងការសម្គាល់
- ដាក់នៅក្នុងទូឯកសារ
- ការទុកតាមលេខកូដ

ដាក់ក្នុងបន្ទប់រក្សាឯកសាររបស់មន្ទីរសារការី ជាអាទិ៍។

### ២.២.២. ការគ្រប់គ្រងឯកសារ

ការគ្រប់គ្រងឯកសារ គឺជាការគ្រប់គ្រងពត៌មានដែលផ្តោតសំខាន់ទៅលើប្រព័ន្ធនៃការវិភាគ និងការត្រួតពិនិត្យមើលអំពីដំណើរឯកសារដែលបានបង្កើត រក្សាទុកដោយភ្នាក់ងាររដ្ឋបាលជាអ្នកមើលការខុសត្រូវឯកសារដែលបានតាក់តែងរួចរាល់ ដើម្បីប្រតិបត្តិនៅពេលកំណត់ណាមួយ។ វិធីសាស្ត្រ និងលក្ខណៈនៃក្នុងការគ្រប់គ្រងឯកសារតាមប្រព័ន្ធរដ្ឋបាលមានដូចជា:

- ការគ្រប់គ្រងតាមលំដាប់អក្សរ ( Ex៖ Aa Ab Ac Ad ……………………….Az.)
- ការគ្រប់គ្រងតាមលេខឋានានុក្រម ៖ គឺរក្សាទុកដោយការបង់លេខ Ex 0000/ ០១៩ ចុះថ្ងៃទី..........ខែ..........ឆ្នាំ ...........។

- ការគ្រប់គ្រងតាមកម្មវត្ថុនៃលិខិត ( បែកចែកតាមជា File Shelve ទៅតាមប្រធានបទ ដើម្បីងាយស្រួលក្នុងការស្វែងរក។ Ex. កិច្ចព្រមព្រៀង កិច្ចសន្យា
- គ្រប់គ្រងតាមលំដាប់ឯកសារដែលបានតាក់តែងមុនតាក់តែងក្រោយ
- ការគ្រប់គ្រងតាមភូមិសាស្ត្រ (Ex. បាត់ដំបង តាកែវ ព្រៃវែង ភ្នំពេញ .ល.)
- ការគ្រប់គ្រងតាម Internet
- ការគ្រប់គ្រងតាមប្រព័ន្ធ Network
- ស្តេនទុកនៅក្នុង Hard drive (រក្សាទុកច្បាប់ដើមទុកក្នុងទូរដាក់ឯកសារ)
- ការដាក់ក្នុង Data Base ឬ File Management
- ការគ្រប់គ្រងនៅក្នុង DOCUMNENT ហើយ Save ឈ្មោះឯកសារនោះ ដើម្បីការពារកុំអោយបាត់បង់។ ហើយការគ្រប់គ្រងនេះទៀតសោតគឺគ្រប់គ្រងឲ្យបានគង់វង្សយូរអង្វែង ហើយមានលក្ខណៈទាក់ទាញទីកន្លែង ។
- ការផ្តល់ព័ត៌មានរហ័ស មិនយឺតយ៉ាវ (ឯកសារត្រឹមត្រូវទៅតាមអង្គភាព) (ត្រឹមត្រូវតាមទម្រង់រដ្ឋបាល)
- ការកត់ត្រារបាយការណ៍ត្រូវធ្វើតាមជំហាននីមួយៗ និងការត្រួតពិនិត្យបានយ៉ាងលម្អិត
- ទទួលស្គាល់សម្រាប់ការទទួលខុសត្រូវប្រតិបត្តិការណ៍ទាំងមូល និងការអនុវត្តន៍កម្មវិធីរក្សាទុកឯកសារ
- ដើម្បីងាយស្រួលក្នុងការស្វែងរក
- ធ្វើការឆ្លើយតបព័ត៌មានទៅវិញទៅមកយ៉ាងឆាប់រហ័ស
- មានទំនើបកម្មក្នុងដៃលើការតម្កល់ឯកសារ កុំឲ្យមានការបាត់បង់។
- ធ្វើឲ្យអតិថិជនមានទំនុបចិត្ត
- មិនមានបញ្ហានៅពេលដល់ពេលប្រតិបត្តិ
- ចំណាយពេលវេលាតិច។

ខាងលើនេះ ចំនុចសំខាន់ដោយសារការគ្រប់គ្រងឯកសារឲ្យបានត្រឹមត្រូវ ហើយមារបៀបរៀបចំទុកដាក់ឲ្យបានត្រឹមត្រូវនិងមានសុវត្ថិភាពងាយស្រួលក្នុងការយកមកប្រើប្រាស់ម្តងៗ និងមានប្រសិទ្ធភាព ហើយធានាបាននូវចរន្តការងារ។

## ២.៣ ការប្រគល់ត្រឡប់

ដើម្បីធានាភាពជឿជាក់ពីសំណាក់ម្ចាស់បណ្តាំ សារការីមានករណីកិច្ច ចេញច្បាប់ចម្លង ឬលិខិតរដ្ឋបាលមួយច្បាប់ទៅម្ចាស់បណ្តាំ ដើម្បីបញ្ជាក់ថាម្ចាស់បណ្តាំបានតាក់តែងលិខិតមតក-សាសន៍របស់ខ្លួននៅមន្ទីរសារការី។ ម៉្យាងវិញទៀតដើម្បីឲ្យសន្តតិជន អច្ច័យលាភី និងជនដែលពាក់ព័ន្ធផលប្រយោជន៍ បានដឹងថាម្ចាសបណ្តាំ បានធ្វើបណ្តាំមតកសាសន៍នៅទីណា ងាយស្រួល ជូនដំណឹងទៅមន្ទីរសារការអំពីមរណភាពរបស់មតកជនដើម្បីឲ្យសារការីចាប់ផ្តើមប្រតិបត្តិមតសាសន៍នៅពេលដែលមតកជន ទទួលមរណភាព។

### ២.៣.១ ការចេញសេចក្តីចម្លង

កន្លងមកតាមរយៈការអនុវត្តមុខងារសារការីតាមមន្ទីរនីមួយៗ នៃព្រះរាជណាចក្រកម្ពុជា ការចេញសេចក្តីចម្លងនៃលិខិតមតកសាសន៍ តម្រូវឲ្យមតកជនធ្វើការស្នើសុំទៅមន្ទីរសារការីដែលខ្លួនបានតាក់តែងលិខិតមតកសាសន៍។ ដោយសារតែ មតកសាសន៍ ជាលិខិតយថាភូត មានតែមួយច្បាប់គត់។ ប្រសិនបើម្ចាស់បណ្តាំចង់បានសេចក្តីចម្លងមតកសាសន៍ជាលិខិតយថាភូត សាការីត្រូវការចម្លងមតកសាសន៍ជាលិខិតយថាភូតជូនម្ចាស់ទៅមតកជន ដោយច្បាប់ចម្លងនោះ មានការបោះត្រាពីប្រធានមន្ទីរសារការី បញ្ជាក់ថា ត្រឹមត្រូវតាមទម្រង់ច្បាប់ដើម។ ដូច្នេះ ជាកាតព្វកិច្ចរបស់សារការី នៅពេលដែលម្ចាស់បណ្តាំស្នើសុំឲ្យសារការីចេញលិខិតចម្លងនៃមតកសាសន៍ជាលិខិតយថាភូត សារការីត្រូវតែចេញច្បាប់ចម្លងជូនទៅមតកជន ហើយត្រូវបញ្ជាក់ថា ច្បាប់ចម្លងនេះ ត្រូវត្រឹមតាមច្បាប់ដើម។

### ៣.២.២ ការរៀបចំថតចម្លង

ជាគោលការណ៍ ការរៀបចំថតចម្លងឯកសារលិខិតមតកសាសន៍ជូនម្ចាស់បណ្តាំរដ្ឋបាលមន្ទីរត្រូវធ្វើដូចជា៖

- ត្រូវយកឯកសារពីកន្លែងរក្សាទុក
- មកស្កេន
- រក្សាទុកនៅក្នុង( Drive)
- ហើយត្រួតពិនត្យឯកសារនោះឲ្យបានច្បាស់លាស់ជាមុនសិន
- ធ្វើការបញ្ជូនឯកសារនោះ ទៅបុគ្គលដែលពាក់ព័ន្ធ (ដូចជា៖ ប្រធានមន្ទីរសារការី អនុ-ប្រធានមន្ទីរសារការី) ជាដើម។

- នៅពេលទទួលបានឯកសារថតចម្លងហើយ ប្រធាន ឬ អនុប្រធានសារការីដែលបានតាក់តែងត្រូវតែពិនិត្យថាត្រូវត្រឹមតាមច្បាប់ដើមឬអត់។
- នៅពេលពិនិត្យត្រឹមត្រូវតាមច្បាប់ដើមរួចហើយ ប្រធាន ឬ អនុប្រធានសារការីដែលបានតាក់តែង ត្រូវចុះហត្ថលេខា និងថ្ងៃបរិច្ឆេទ ដើម្បីបញ្ជាក់ថាបានថតចម្លង និងពិនិត្យត្រូវត្រឹមអស់ហើយ។
- បន្ទាប់មកមន្ត្រីដែលរៀបចំថតចម្លងត្រូវបោះត្រា ដើម្បីបញ្ជាក់ថា ត្រូវត្រឹមតាមច្បាប់ដើម និងស្របតាមទម្រង់ច្បាប់ បញ្ជាក់ពីយថាភាពនៃលិខិត និងមានអានុភាពដូចច្បាប់ដើម។
- ត្រូវប្រគល់ឯកសារនោះ ទៅម្ចាស់បណ្តាំ ហើយម្ចាស់បណ្តាំត្រូវចុះហត្ថលេខា និងថ្ងៃបរិច្ឆេទថាខ្លួនទទួលលិខិតថតចម្លងនេះ ត្រូវត្រឹមតាមច្បាប់ដើម និងស្របតាមឆន្ទះរបស់ខ្លួនពិតប្រាកដមែន។
- ឬមួយទៀតបើម្ចាស់បណ្តាំមិនបានមកផ្ទាល់ទេ ត្រូវបញ្ជូនឯកសារនោះ តាមប្រព័ន្ធ អ៊ីម៉ែល (Email) ឬ ប្រព័ន្ធផ្សព្វផ្សាយសង្គម ( Social Media) ។

## ២.៤ ការកំណត់តម្លៃសេវារក្សាទុក

ជាក់ស្តែក ការប្រតិបត្តិមុខងាររបស់សារការីមកទល់ពេលបច្ចុប្បន្ននេះ នូវមិនទាន់មានច្បាប់ និងបទដ្ឋានគតិយុត្តិណាមួយ កំណត់តម្លៃក្នុងការរក្សាទុកលិខិតបណ្តាំមតកសាសន៍ដែលសារការីបានតាក់តែងនោះទេ ហើយដោយសារតែគ្មានច្បាប់មិនទាន់បានកំណត់អំពីតម្លៃសេវាច្បាស់លាស់នោះ ទេ ទើបតម្លៃនោះគឺអាស្រ័យទៅលើមន្ទីរនៃសារការីនីមួយៗជាអ្នកកំណត់អំពីតម្លៃនោះ ។

### ២.៤.១ តម្លៃតាមការព្រមព្រៀងក្នុងការរក្សាទុក

មកទល់បច្ចុប្បន្ននេះ តួនាទីក្នុងការរក្សាទុកលិខិតមតកសាសន៍របស់សារការី ពុំទាន់ឃើញមានបទដ្ឋានគតិយុត្តិ និងច្បាប់ណាមួយកំណត់អំពីតម្លៃក្នុងការរក្សាទុកលិខិតមតកសាសន៍របស់សារការីនោះទេ។ ប៉ុន្តែបើតាមការអនុវត្តន៍ជាក់ស្តែង នៅពេលដែលសារការីធ្វើការតាក់តែងលិខិតមតកសាសន៍ និងទទួលយកលិខិតបណ្តាំពីមតកជន សារការីត្រូវចចារជាមួយមតកជនជាមុនសិនដោយសេរី អំពីការកំណត់តម្លៃក្នុងរក្សាទុកលិខិតតមកសាសន៍។ តាមរយៈការប្រើប្រាស់សេវាសារការីមុននឹងមតកជន មកពឹងពាក់សេវាសារការី ក្នុងការតាក់តែង និងការរក្សាទុកនូវលិខិតមតក-សាសន៍ ដើម្បីធានាបាននូវសុវត្ថិភាព នៃខ្លឹមសារមតកសាសន៍ និងត្រឹមត្រូវតាមទម្រង់ច្បាប់របស់មតកជន ត្រូវធ្វើការចរចា និងព្រមព្រៀងជាមួយសារការី លើតម្លៃក្នុងការរក្សាទុក។ សារការី ត្រូវតែសិក្សាឲ្យច្បាស់ពីទំហំមតកសាសន៍ និងផលប៉ះពាល់ក្នុងការរក្សាទុក ជាមួយមតកជន នូវតម្លៃក្នុង

ការក្នុងការរក្សាទុកបានជាក់លាក់ហើយតម្លៃតាមការព្រមព្រៀងក្នុងការរក្សាទុកលិខិតមតសាសន៍ខាងលើ តម្រូវឲ្យម្ចាស់បណ្តាំ និងសារការី យល់ព្រមដោយឆន្ទៈពិតប្រាកដដោយសេរី ក្នុងការទទួលយកតម្លៃ និងយល់ព្រមក្នុងការផ្តល់តម្លៃជូនសារការី ដោយមិនមានបង្ខិតបង្ខំ ពីសំណាក់ សន្តតិជន អច្ច័យលាភី ឬជនពាក់ព័ន្ធផលប្រយោជន៍ឡើយ។

## ២.៤.២ តម្លៃតាមទំហំមតកសាសន៍ក្នុងការព្រមព្រៀង

សារការី នៅពេលគាត់តែងលិខិតមតកសាសន៍ និងទទួលយកបណ្តាំពីមតកជន មកថែរក្សាទុក សារការីត្រូវតែសិក្សាពីទំហំនៃមកតសាសន៍ច្បាស់លាស់ មុននិងសារការីកំណត់តម្លៃជាមួយមតកជន។ ដោយសារថា ការកំណត់បែបនេះ ពីព្រោះ មតកសាសន៍កាន់តែធំ សកម្មភាពការងាររបស់សារការីកាន់តែច្រើន និងហានីភ័យក្នុងការទទួលខុសត្រូវកាន់តែខ្ពស់។ ការកំណត់តម្លៃតាមទំហំមតកសាសន៍បែបនេះ ដើម្បីឲ្យមានភាពសមាមាត្រនៃសកម្មភាពការងាររបស់សារការី និងឲ្យមានតម្លាភាពនៃមន្ទីរសារការី ក្នុងការរក្សាលិខតិមតកសាសន៍អោយបានគង់វង្ស និងសុវត្ថិភាពរហូតដល់ការចាប់ផ្តើមប្រតិបត្តិមតកសាសន៍។

# ជំពូកទី៣

# តួនាទីសារការីក្នុងការប្រតិបត្តិមតកសាសន៍

ការប្រតិបត្តិមតកសាសន៍ ជាដំណាក់កាលនៃការអនុវត្តមតកសាសន៍។ ជាគោលការណ៍ មតកសាសន៍នឹងត្រូវអនុវត្តនៅពេលមរណភាពរបស់ម្ចាស់បណ្តាំ។

ក្នុងការប្រតិបត្តិមតកសាសន៍ សារការីក៏មានតួនាទីផងដែរ នៅពេលសារការីទទួលយកមុខងារជាអ្នកប្រតិបត្តិ។ នៅក្នុងជំពូកទី៣ យើងខ្ញុំនឹងធ្វើការបកស្រាយអំពីតួនាទីសារការីក្នុងការប្រតិបត្តិមតកសាសន៍ ដែលមានដូចជា៖ ការចាប់ផ្តើមតួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ ( ៣.១) តួនាទីក្នុងការប្រតិបត្តិមតកសាសន៍( ៣.២) និងការបញ្ចាប់តួនាទីក្នុងការប្រតិបត្តិមតកសាសន៍ ( ៣.៣)។

## ៣.១. ការចាប់ផ្តើមតួនាទីជាអ្នកប្រតិបត្តិមតកសាសន៍

ជាទូទៅការចាប់ផ្តើមតួនាទីជាអ្នកប្រតិបត្តិមតកសាសន៍ គឺនៅពេលដែលមតកជនបានទទួលមរណភាព ហើយម្ចាស់បណ្តាំបានប្រគល់អាណត្តិឲ្យសារការីជាប្រតិបត្តិមតកសាសន៍តាមខ្លឹមសារនៃលិខិតបណ្តាំ ហើយសារការីត្រូវទទួលបានអាណត្តិក្នុងការចាប់ផ្តើមជាអ្នកប្រតិបត្តិមតកសាសន៍ សារការីត្រូវជូនដំណឹងនោះទៅឲ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ[14]។

ហើយដើម្បីឲ្យមានភាពកាន់តែច្បាស់អំពីការចាប់ផ្តើមតួនាទី ជាអ្នកប្រតិបត្តិមតកសាសន៍ថែមទៀតនោះគឺត្រូវសិក្សានូវចំណុចដូចខាងក្រោម៖ អ្វីទៅការចាប់សន្តតិកម្ម និងការយល់ព្រមកាន់កាប់មុខងារជាអ្នកប្រតិបត្តិ (៣.១.១) អ្វីទៅ ការបើក និងការពិនិត្យបញ្ជាក់មតកសាសន៍ (៣.១.២) ។

### ៣.១.១. ការចាប់ផ្តើមសន្តតិកម្ម និងការយល់ព្រមកាន់កាប់មុខងារជាអ្នកប្រតិបត្តិ

#### ៣.១.១.១. ការចាប់ផ្តើមសន្តតិកម្ម

សន្តតិកម្ម ជាទូទៅមានអានុភាពនៅពេលដែលមតកជនបានទទួលមរណភាព ។ សន្តតិកម្មមួយអាចអនុវត្តបាន ត្រូវគោរពនូវលក្ខខណ្ឌដែលមានចែងនៅក្នុងមតកសាសន៍ ទើបសន្តតិកម្មនោះមានសុពលភាពក្នុងការអនុវត្ត។ ជាក់ស្តែង សន្តតិកម្មដែលអាចចាត់ទុកថា មានសុពលភាព ត្រូវគោរពលក្ខខណ្ឌដែលច្បាប់បានតម្រូវ ជាពិសេសក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[14] មាត្រា ១២១៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

ការបើកសន្តតិកម្ម គឺត្រូវធ្វើឡើងនៅចំពោះមុខ សន្តតិជន អច្ច័យលាភី ឬជនដែលពាក់ព័ន្ធផលប្រយោជន៍នៃលិខិតមតកសាសន៍ ព្រមទាំងមានវត្តមានសារការីជាអ្នកប្រិតបត្តិមតកសាសន៍ ដែលគាត់ទទួលអាណត្តិជាអ្នកប្រតិបត្តិមតកសាសន៍ ស្របតាមឆន្ទៈរបស់មតកជន នៅពេលគាត់តែងលិខិតមតកសាសន៍ កាលមតកជននៅរស់។

### ៣.១.១.២. ការយល់ព្រមកាន់កាប់មុខងារជាអ្នកប្រតិបត្តិ

នៅពេលដែលសន្តតិកម្មបានចាប់ផ្តើម ហើយមានលិខិតមតកសាសន៍ដែលបានកំណត់សារការីជាអ្នកប្រតិបត្តិមតកសាសន៍ សារការីដែលជាអ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវអនុវត្តភារកិច្ចនោះភ្លាមៗ[15]។ ប្រសិនបើលិខិតមតកសាសន៍បានកំណត់សារការីជាអ្នកប្រតិបត្តិមតសាសន៍ ហើយសារការីមិន បានឆ្លើយយល់ព្រមក្នុងការកាន់កាប់មុខងារបន្ទាប់ពីសន្តតិកម្មបានចាប់ផ្តើមទេ សន្តតិជន ឬអច្ច័យលាភី និងដែលនពាក់ព័ន្ធផលប្រយោជន៍ផ្សេងទៀត អាចកំណត់អំឡុងពេលសមរម្យ ហើយដាស់តឿនចំពោះសារការី ឲ្យឆ្លើយបញ្ជាក់យ៉ាងច្បាស់លាស់ក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬមិនយល់ព្រមកាន់កាប់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍[16]។ ក្នុងករណីដែលសារការីជាអ្នកប្រតិបត្តិមតកសាសន៍ មិនបានឆ្លើយបញ្ជាក់ក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថាសារការីបានលាឈប់ពីការងារ[17]។ ប្រសិនបើគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេ ឬ ក៏បាត់បង់អ្នកប្រតិបត្តិមតកសាសន៍ សន្តតិជន ឬអច្ច័យលាភី និងអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍អាចទារទាមឲ្យតុលាការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍បាន ដូចមានកំណត់នៅក្នុងមាត្រា ១២១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មតកសាសន៍នោះផងដែរ ។

## ៣.១.២. ការបើក និងការពិនិត្យបញ្ជាក់មតកសាសសន៍

### ៣.១.២.១. ភាពចាំបាច់នៃការបើក និងការពិនិត្យបញ្ជាក់

ជាការកំណត់ដោយច្បាប់ នៅពេលដែលមតកជននេះបានទទួលមរណភាពដោយបន្សល់ទុកនូវលិខិតមតកសាសន៍ដែលជាការបង្ហាញឆន្ទៈចុងក្រោយមុនទទួលមរណភាព តម្រូវឲ្យមានការបើក នឹងមានការពិនិត្យបញ្ជាក់លើលិខិតមតកសាសន៍នៅតុលាការ ងាយស្រួលដើម្បីធ្វើការបញ្ជាក់នូវលិខិតបណ្តាំនោះ តើលិខិតបណ្តាំដែលយកមកពិនិត្យនេះ ពិតជាបានធ្វើឡើងដោយដៃផ្ទាល់ ឬប្រាប់ដោយផ្ទាល់មាត់ទៅសារការីដើម្បីធ្វើការតាក់តែងបណ្តាំលិខិតមតកសាសន៍ជាលិខិយថាភូត

15 មាត្រា ១២១៥ នៃក្រមរដ្ឋវេណីឆ្នាំ ២០០៧
16 មាត្រា ១២១៦ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
17 មាត្រា ១២១៦ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

របស់មតកជនកាលនៅរស់ពិតឬយ៉ាងណា។ ម៉្យាងវិញទៀតការពិនិត្យបញ្ជាក់នូវលិខិតមតសាសន៍ គឺធ្វើឡើងដើម្បីឲ្យសន្តតិជន ឬអច្ច័យលាភី និងជនដែលពាក់ព័ន្ធផលប្រយោជន៍បានដឹងលឺ និង ដើម្បីកំណត់នូវខ្លឹមសារនៃមតកសាសន៍នោះ ជៀសវាងកុំឲ្យមានការលួចកែប្រែក្រោយការ ពិនិត្យបញ្ជាក់នោះ។[18]

គួរឲ្យកត់សម្គាល់ផងដែរថា ការពិនិត្យបញ្ជាក់មតកសាសន៍ដែលបានរាប់រៀបខាងលើ គឺមិនមែនជាការពិនិត្យទៅលើលក្ខខណ្ឌសុពលភាពនៃមតកសាសន៍នោះទេ ដូចនេះ ប្រសិនបើមានហេតុណាមួយដែលអាចធ្វើឲ្យលិខិតមតកសាសន៍មោឃភាព អ្នកដែលមានផលប្រយោជន៍ពាក់ព័ន្ធអាចដាក់ពាក្យបណ្ដឹងទៅតុលាការដើម្បីធ្វើការបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍នោះ ជាដើម ។[19]

ទោះបីជាយ៉ាងនេះក្ដី មិនមែនគ្រប់លិខិតមតកសាសន៍សុទ្ធតែចាំបាច់ត្រូវឆ្លងកាត់នីតិវិធីនៃការពិនិត្យបញ្ជាក់ឡើយ។ ឧទាហរណ៍៖ គឺលិខិតមតកសាសន៍ដែលតាក់តែងឡើយដោយសារការី ត្រូវចាត់ទុកថា ជាមតកសាសន៍ជាលិខិតយថាភូត ហើយមានអានុភាពស្មើសាលក្រម ឬសាលដីកាអាចអនុវត្តភ្លាម។ ដូច្នេះ នៅពេលចាប់ផ្ដើមសន្តតិកម្ម លិខិតមតកសាសន៍ ដែលបានតាក់តែងដោយសារការី មិនចាំបាច់ទាមទារការពិនិត្យបញ្ជាក់ទេ វាអាចបើកសន្តតិកម្មបាន។ ក្រៅពីលិខិតមតកសាសន៍ដែលធ្វើឡើងជាលិខិតយថាភូត សុទ្ធតែជាកម្មវត្ថុនៃកាធ្វើពិនិត្យបញ្ជាក់ទាំងអស់។

### ៣.១.២.២. ភាពចាំបាច់នៃហេតុដែលត្រូវគោរពមុន

នៅក្នុងមាត្រា ១២១៣ នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តិថា អ្នកថែរក្សាគ្រប់គ្រង់លិខិតមតក-សាសន៍ឬ សន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត ដែលបានរកឃើញលិខិតមតក-សាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការដោយគ្មានការយឺតយ៉ាវហើយ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម គឺ លើកលែងតែលិខិតមតកសាសន៍នោះជាលិខិតយថាភូត ។ ចំពោះលិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបាននៅចំពោះមុខតុលាការប៉ុណ្ណោះ ដោយមានវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន អច្ច័យលាភី ឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬអ្នកតំណាងរបស់ជននោះ បើពុំនោះទេនឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១.០០០.០០០ (មួយលាន) រៀល[20]។ ទោះបីជាលិខិត

[18] វ៉ៃ ភីរក្ស សិស្សសារការីជំនាន់ទី២ *កិច្ចការស្រាវជ្រាវ ការប្រតិបត្តិមតកសាសន៍* (សាលាភូមិន្ទសារការី,២០១៨),ទំព័រ ២.
[19] វ៉ៃ ភីរក្ស សិស្សសារការីជំនាន់ទី២ *កិច្ចការស្រាវជ្រាវ ការប្រតិបត្តិមតកសាសន៍* (សាលាភូមិន្ទសារការី,២០១៨),ទំព័រ ២.
[20] មាត្រា ១២១៣ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

មតកសាសន៍នោះបានបើកនៅក្រៅតុលាការក៏ដោយ ក៏លិខិតនោះមិនត្រូវបាត់បង់អានុភាពឡើយ[21] ។

#### ៣.១.២.៣. លិខិតមតកសាសន៍ទទួលការពិនិត្យបញ្ជាក់

នៅពេលដែលលិខិតមតកសាសន៍ទទួលបានការពិនិត្យបញ្ជាក់ និងមានភាពត្រឹមត្រូវច្បាស់លាស់រួចហើយ នាំឲ្យលិខិតមតសាសន៍នោះមានអានុភាព និងអាចអនុវត្តបានទៅតាមការប្រតិបត្តិមតកសាសន៍នោះ ។ ការពិនិត្យបញ្ជាក់លិខិតមកសាសន៍ គឺមានបំណងបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍ ដើម្បីឲ្យមានភាពច្បាស់លាស់ចំពោះឆន្ទៈពិតប្រាដករបស់មតកជន និងគោរពលក្ខខណ្ឌទម្រង់មតកសាសន៍ ដែលច្បាប់បានកំណត់ ។ ករណីលិខិតមតក-សាសន៍មានច្រើនច្បាប់ ត្រូវពិនិត្យទម្រង់ និងខ្លឹមសារនិងអត្ថបទ ហើយប្រសិនបើត្រូវនឹងលក្ខខណ្ឌនៃការលុបចោលមតកសាសន៍ ត្រូវអនុវត្តតាមទម្រង់នៃការលុបចោលនោះ។

## ៣.២. តួនាទីក្នុងការប្រតិបត្តិមតកសាសន៍

តួនាទីក្នុងការប្រតិបត្តិមតកសាសន៍ ជាអ្នកដែលបានជ្រើសតាំងដើម្បីប្រតិបត្តិមតកសាសន៍ហេតុនេះហើយ ត្រូវផ្តល់សិទ្ធិ និងករណីយកិច្ច ដើម្បីគ្រប់គ្រងមតិក និងធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ឲ្យស្របតាមខ្លឹមសារនៃលិខិតបណ្តាំដែលសារការីបានតាក់តែងដោយមានការប្រាប់ដោយផ្ទាល់មាត់ពីមតកជន និងតាមបញ្ញត្តិនៃមាត្រា ១២២០ នៃសេចក្តីកំណត់ក្រម ឆ្នាំ២០០៧។ ហើយសារការី នៅពេលដែលខ្លួនដើរតួនាទីក្នុងការប្រតិបត្តិមតក-សាសន៍ សារការីត្រូវគោរពតាម ឆន្ទៈរបស់ម្ចាស់បណ្តាំ ព្រមទាំងស្របតាមខ្លឹមសារនៃលិខិតបណ្តាំ និងគោរពតាមបញ្ញត្តិនៃច្បាប់ផងដែរ។ ដើម្បីឲ្យមានសភាពត្រឹមត្រូវ ជាពិសេសគឺឲ្យមានអានុភាព និងឲ្យសមស្របទៅតាមតួនាទីរបស់សារការីក្នុងការប្រតិបត្តិមតកសាសន៍គប្បីស្វែងយល់៖ អ្វីទៅការធ្វើបញ្ជីសារពើភណ្ឌ ( ៣.២.១) ការគ្រប់គ្រង់មតិក (៣.២.២) ការប្រតិបត្តិតាមខ្លឹមសារនៃមតកសាសន៍ (៣.២.៣) ការជ្រើសតាំងបន្ត (៣.២.៤) សហប្រតិបត្តិ (៣.២.៥.) និង សោហ៊ុយ (៣.២.៦)។

### ៣.២.១. ការធ្វើបញ្ជីសារពើភ័ណ្ឌ

ក្រោយពីសារការីបានកាន់កាប់មុខងារ ជាអ្នកប្រតិបត្តិមតកសាសន៍ ជាដំបូងសារការី ត្រូវធ្វើបញ្ជីសារពើភណ្ឌនៃទ្រព្យសម្បត្តិ ហើយត្រូវប្រគល់បញ្ជីសារពើភណ្ឌនោះទៅឲ្យសន្តតិជន ដោយ

[21] មាត្រា ១២១៣ កថាខណ្ឌទី៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

គ្មានការយឺតយ៉ាវ[22]។ ក្នុងករណីដែលសារការីជាអ្នកប្រតិបត្តិមតកសាសន៍គាត់ត្រូវធ្វើបញ្ជីសារពើភណ្ឌនៃទ្រព្យសម្បត្តិ សន្តតិជនអាចអវត្តមានបាន[23]។

គួរកត់សម្គាល់ផងដែលថា មូលហេតុដែលក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៅដែលខ្លួនចាប់ផ្តើមកាន់កាប់មុខងារដំបូង គឺដើម្បីកំណត់ឲ្យមានភាពច្បាស់លាស់នូវមតិករបស់មតកជននៅពេលចាប់ផ្តើមសន្តតិកម្ម ដែលជាកម្មវត្ថុនៃសិទ្ធក្នុងការគ្រប់គ្រងចាត់ចែងមតិករបស់អ្នកប្រតិបត្តិមតកសាសន៍ ព្រមទាំងដើម្បីបញ្ជាក់អំពីមូលដ្ឋាននៃករណីយកិច្ចប្រគល់ ករណីកិច្ចរាយការណ៍ និងករណីយកិច្ចសងសំណងរបស់សារការីក្នុងការប្រតិបត្តិមតកសាសន៍ ជាដើម ។ ទោះជាយ៉ាងនេះក្តី ការរៀបចំបញ្ជីសារពើភ័ណ្ឌអាចអនុវត្តទៅបានតែចំពោះទ្រព្យសម្បត្តិជាក់លាក់ដែលបានកំណត់នៅ លិខិតមតកសាសន៍តែប៉ុណ្ណោះ[24]។ ដូច្នេះក្នុងករណីដែលខ្លឹមសារនៃលិខិតបណ្តាំរបស់មតកជន មានចែងអំពីសិទ្ធិនិងករណីយកិច្ចរបស់សារការីក្នុងការប្រតិបត្តិមតកសាសន៍ សារការីត្រូវអនុវត្តតែចំពោះទ្រព្យសម្បត្តិមួយភាគនោះប៉ុណ្ណោះ មិនអាចអនុវត្តលើសពីទ្រព្យដែលមតកជនបានចែងនោះទេ ។

នៅពេលដែលសារការីជាអ្នកប្រតិបត្តិមតកសាសន៍បានចាប់ផ្តើមកាន់កាប់មុខងាររបស់ខ្លួន សន្តតិជនពុំអាចចាត់ចែងមតិក ឬធ្វើសកម្មភាពផ្សេងទៀត ដែលនាំឲ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ[25] ។ ហើយម្យ៉ាងទៀតនោះ សន្តតិជនមិនអាចទៅធ្វើនូវសកម្មភាពដែលប៉ះពាល់ដល់ការប្រតិបត្តិដល់អ្នកប្រតិបត្តិមតកសាសន៍នោះទេ ។

### ៣.២.២. ការគ្រប់គ្រងមត៌ក

សារការី មានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងថែរក្សាមតិក និងធ្វើរាល់សកម្មភាពផ្សេង ទៀតដែលចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍ឲ្យស្របតាមខ្លឹមសារនៃលិខិតបណ្តាំ[26]។

ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត[27]។ សារការីដែលបានធ្វើការជ្រើសតាំងដើម្បីធ្វើជាអ្នកប្រតិបត្តមតកសាសន៍ ត្រូវធ្វើសកម្មភាពមួយចំនួនដែលពាក់ព័ន្ធនឹងការគ្រប់គ្រង

[22] មាត្រា១៨១៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[23] មាត្រា១៨១៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[24] មាត្រា១២២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[25] មាត្រា ១២២១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[26] មាត្រា ១២២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[27] មាត្រា ៦៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

មតិក ដែលសកម្មភាពនោះមានដូចជា ការមើលថែទាំ ការជួលជុល ការប្រមូលផលស៊ីវិល ឬ ផលធម្មជាតិ ជាដើម ។

### ៣.២.៣. ការប្រតិបត្តិតាមខ្លឹមសារនៃមតកសាសន៍

ជាធម្មតា នៅពេលដែលសន្តតិកម្មចាប់ផ្តើមដោយមានវត្តមាននៃលិខិតមតកសាសន៍ នោះ បញ្ញត្តិស្តីពីសន្តតិកម្មតាមមតកសាសន៍ត្រូវយកមកអនុវត្ត។ បន្ថែមលើសពីនេះទៀត បើមតកជនបានកំណត់ចំណែកមតិក ឬវិធីបែកចែកនូវមតិកនោះ សាកាវីត្រូវធ្វើការបែងចែកត្រូវតែគោរពទៅតាមការកំណត់របស់មតកជនទៅឲ្យសន្តតិជនច្រើនអ្នក ឬតែម្នាក់ដោយមតកសាសន៍នោះត្រូវធ្លាក់ទៅលើសន្តតិជន ដែលត្រូវទទួលនូវមតកសាសន៍។ ដូចនេះបើខ្លឹមសារនៃមតកសាសន៍ជាការប្រគល់នូវវត្ថុអ្វីមួយ នោះសារការីត្រូវប្រគល់នូវវត្ថុនោះឲ្យទៅសន្តតិជនដែលត្រូវទទួល ហើយប្រសិនបើវត្ថុនោះជាអចលនវត្ថុវិញ សារការីត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិមកឲ្យសន្តតិជនដែលត្រូវទទួលបានផងដែរ ។[28]

### ៣.២.៤. ការជ្រើសតាំងបន្ត

សារការី អាចជ្រើសតាំងតតិយជនណាម្នាក់ឲ្យអនុវត្តភារកិច្ចជំនួសខ្លួនបាន តែក្នុងករណីដែលមានមូលហេតុដែលពុំអាចជៀសវាងបាន[29] តែប៉ុណ្ណោះលើកលែងតែករណីដែលមតកជនបានបង្ហាញឆន្ទៈផ្សេង[30]។ ប្រសិនបើសារការី បានឲ្យតតិយជនអនុវត្តនូវភារកិច្ចរបស់ខ្លួនដោយមានមូលហេតុសមរម្យ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំងបន្ត និងការត្រួតពិនិត្យជននោះ ចំពោះអច្ច័យលាភី និងសន្តតិជន។

ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍បន្ត ពីសារការីមានកំហុសនៅពេលដែលប្រតិបត្តិមតកសាសន៍ អ្នកប្រតិបត្តមតកសាសន៍ពុំអាចលើកលែងអំពីភាពគ្មានកំហុសរបស់ខ្លួន ដើម្បីឲ្យរួចផុតពីការទទួលខុសត្រូវចំពោះ អច្ច័លាភី និងសន្តតិជនបានឡើយ។ ដោយសារតែនៅក្នុងបទបញ្ញត្តិស្តីពីសន្តតិកម្មតាមមតសាសន៍ ក៏ដូចជាបទបញ្ញត្តិស្តីពីអាណត្តិ គឺពុំបានបញ្ញត្តិអំពីការអនុវត្តជំនួសនោះទេ ដោយសារវាផ្ទុយនឹងឆន្ទៈរបស់មតកជន ដែលខ្លួនបានកំណត់ក្នុងលិខិតបណ្តាំ។

---

[28] វ៉ៃ ភីរក្ស សិស្សសារការីជំនាន់ទី២ *កិច្ចការស្រាវជ្រាវ ការប្រតិបត្តិមតកសាសន៍* (សាលាភូមិន្ទសារការី,២០១៨),ទំព័រ ៧.

[29] មូលហេតុដែលក្រមរដ្ឋប្បវេណីហាមឃាត់មិនអនុញ្ញាតឲ្យអ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិជ្រើសតាំងតតិយជនដោយសេរីប្រសិនបើគ្មានមូលហេតុសមរម្យ ដោយសារតែមតកជនមានជំនឿទុកចិត្តទៅលើចំនេះដឹង ដូចជាសមត្ថភាពរបស់អ្នកប្រតិបត្តិមតកសាសន៍ ។

[30] មតកជនអាចចែងក្នុងមតកសាសន៍ថា ទោះបីជាគ្មានមូលហេតុដែលពុំអាចជៀសវាងបានក៏ដោយ ក៏អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិជ្រើសតាំងតតិយជនឲ្យអនុវត្តការប្រតិបត្តិមតកសាសន៍ផងដែរ

ដោយឡែក ក្នុងករណីដែលសារការី បានឲ្យតតិយជនអនុវត្តភារកិច្ចជំនួស ដោយគ្មានមូលហេតុដែលអាចជៀសវាងបានទេ នោះត្រូវសងសំណងនៃការខូចខាតដែលកើតឡើងដោយសារមូលហេតុនោះ ចំពោះអច្ច័យលាភី និងសន្តតិជន ឬជនពាក់ព័ន្ធផលប្រយោជន៍ផ្សេងទៀត ។ សារការីត្រូវសងនៃការខូចខាត ដោយសារតែវាជាការមិនបំពេញករណីកិច្ច ព្រោះថាមតកជនបានកំណត់បុគ្គលដែលគាត់មានទំនុបចិត្តដើម្បីប្រតិបត្តិមតកសាសន៍។ បើសារការី បានកំណត់ឲ្យបុគ្គលផ្សេងធ្វើកិច្ចការជំនួសខ្លួននោះវានឹងផ្ទុយនឹងឆន្ទៈរបស់មតកជន ។ [31]

### ៣.២.៥. សហប្រតិបត្តិ

យោងទៅតាមមាត្រា ១២២៥ កថាខណ្ឌទី១ បានកំណត់ថាយ៉ាងច្បាស់ថា នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ ការអនុវត្តភារកិច្ចនោះត្រូវសម្រេចលើសពីពាក់កណ្តាល ប៉ុន្តែបើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

ដោយឡែកចំពោះករណីធ្វើសម្មភាពរក្សាទុកវិញសារការីនីមួយៗអាចធ្វើដោយឯកឯងបានដោយមិនចាំបាច់អនុវត្តភារកិច្ចរួមគ្នាឡើយ[32] ។

## ៣.៣. សោហ៊ុយអ្នកប្រតិបត្តិ

សោហ៊ុយដែលទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមតិក ប៉ុន្តែមិនអាចកាត់បន្ថយភាគបម្រុង ដោយសារសោហ៊ុយបន្ទុកនោះឡើយ[33]។ សោហ៊ុយនៃការប្រតិបត្តិមតក-សាសន៍នោះមានដូចខាងក្រោម៖

### ៣.៣.១. កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ គឺជាអ្នកដែលត្រូវបានជ្រើសតាំងដើម្បីប្រតិបត្តិមតកសាសន៍ ហើយត្រូវបានផ្តល់សិទ្ធិ និងករណីយកិច្ច ដើម្បីគ្រប់គ្រងមតិក និងធ្វើរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ហើយជាពិសេស នៅពេលប្រតិបត្តិមតកសាសន៍ សារការីត្រូវចាត់ចែងកិច្ចការនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ផងដែរ។

[31] វ៉ៃ ភីរក្ស របស់សិស្សសារការីជំនាន់ទី២ *កិច្ចការស្រាវជ្រាវ ការប្រតិបត្តិមតកសាសន៍* (សាលាភូមិន្ទសារការី,២០១៨), ទំព័រ ១១.

[32] មាត្រា ១២២៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[33] មាត្រា ១២២៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ដូចនេះ ជាការតបស្នងទៅនឹងការប្រតិបត្តិមតកសាសន៍ អ្នកប្រតិបត្តិមតកសាសន៍មតក-សាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន[34]។ ប៉ុន្តែ ប្រសិនបើមតក-សាសន៍បានបង្ហាញឆន្ទៈនៅក្នុងមតកសាសន៍ថា អ្នកប្រតិបត្តិមតកសាសន៍ពុំទទួលបានកម្រៃទេ អ្នកប្រតិបត្តិមតកសាសន៍នោះ និងមិនទទួលបានកម្រៃឡើយ។ គួរគត់សម្គាល់ផងដែរថា ការប្រតិបត្តិមតកសាសន៍ប្រៀបដូចជាកិច្ចការអាណត្តិ ហេតុដូច្នេះហើយ ទើបមាត្រា ១២២៩ បានបញ្ញត្តិអំពីការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីអាណត្តិ។ ហេតុដូច្នេះនេះហើយ ទើបយើងអាចកំណត់បានថា ការងារប្រតិបត្តិមតកសាសន៍អាចទទួលកម្រៃ ឬ មិនទទួលកម្រៃ ដូចនិងកិច្ចសន្យាអាណត្តិដែរ។

មូលហេតុដែលមតកជនបានកំណត់ថា អ្នកប្រតិបត្តិមតកសាសន៍មិនទទួលបានកម្រៃនៅក្នុងការប្រតិបត្តិមតកសាសន៍ ដោយសារតែ អ្នកប្រតិបត្តិមតកសាសន៍នោះ អាចជាសន្តតិជន ឬជាអច្ច័យលាភី ដែលទទួលបាននូវផលប្រយោជន៍ពីតមកជនហើយ ដូចនេះ ការទទួលបាននូវកម្រៃពីការប្រតិបត្តិមតកសាសន៍ គឺជាការសមរម្យ។ ប៉ុន្តែ ប្រសិនបើមតកសាសន៍បានកំណត់តតិយជនដែលគ្មានទទួលផលប្រយោជន៍ពីសន្តតិជនឲ្យធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ នោះពុំមានភាពសមរម្យឡើយ ប្រសិនបើគាត់ធ្វើការងារដោយពុំទទួលបានកម្រៃ។ ទោះជាយ៉ាងនេះក្តី ប្រសិនបើហេតុនោះបានកើតឡើយ កាត់អាចបដិសេធមិនកាន់មុខងារបាន។

នៅក្នុងករណីដែលមតកសាសន៍ពុំបានកំណត់អំពីកម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមតិក ទំនាក់ទំនងរវាងម្ចាស់បណ្តាំ និងអ្នកប្រតិបត្តិមតកសាសន៍ និងស្ថានភាពផ្សេងៗទៀត[35]។

ឧទាហរណ៍: ការយកជំនាញផ្នែកច្បាប់ដូចជា សារការី ឬ មេធាវី ជាអាទិ៍ មកធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ត្រូវផ្តល់កម្រៃឲ្យបានសមរម្យក្នុងការប្រតិបត្តិមតកសាសន៍នោះ។

ជាការអនុវត្តជាក់ស្តែង នៅពេលដែលមតកជន បានធ្វើមតកសាសន៍ជាលិខិតយថាភូតមតកជន ភាគច្រើនតែងតែកំណត់សារការីជាអ្នកប្រតិបត្តិមតកសាសន៍ ដោយសារតែសារការីជាអ្នកជំនាញផ្នែកច្បាប់ ជាពិសេសគាត់ជាអ្នកតាក់តែងលិខិតមតកសាសន៍នេះតែម្តង។ ដូច្នេះសារការីត្រូវយល់ដឹងពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ។ ម្យ៉ាងវិញទៀត ចំពោះកម្រៃនៃការប្រតិបត្តិមតក-

[34] មាត្រា ១២២៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[35] មាត្រា ១២២៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

សាសន៍ ជាទូទៅ គឺត្រូវបានកំណត់នៅក្នុងមតកសាសន៍ ផងដែរ។ ដូចនេះ ករណីនៃការដាក់ពាក្យបណ្តឹងសុំឲ្យតុលាការកំណត់អំពីកម្រៃនិងពុំមានអត្ថិភាពឡើយ។

### ១.២.៣ សោហ៊ុយផ្សេងទៀតក្រៅពីកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍ ក្រៅពីកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍អាចមានដូចជា៖

- សោហ៊ុយគ្រប់គ្រងមតិក
- សោហ៊ុយធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ
- សោហ៊ុយចាំបាច់សម្រាប់នីតិវិធីពិនិត្យបញ្ជាក់លិខិតមតកសាសន៍
- សោហ៊ុយដាក់ពាក្យសុំកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន
- សោហ៊ុយដាក់ពាក្យសុំផ្តាច់មតិក ឬលុបចោលនូវការផ្តាច់មតិកពីសន្តតិជន ដោយមតកសាសន៍
- សោហ៊ុយទាក់ទងនឹងការចុះសំបុត្រកំណើតរបស់កូននៅក្នុងសៀវភៅកំណើត (ការទទួលស្គាល់កូន) ជាអាទ៍។

នៅក្នុងមាត្រា ១២២៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានកំណត់ថា សោហ៊ុយដែលទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមតកសាសន៍ ប៉ុន្តែ មិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះឡើយ។

## ៣.៤. ការបញ្ចប់តួនាទីក្នុងការប្រតិបត្តិមតកសាសន៍

ជាទូទៅនៅពេលដែលសារការី បានប្រតិបត្តិទៅតាមមតកសាសន៍ និងបំពេញនូវតួនាទីរបស់ខ្លួន រួចរាល់អស់ហើយនោះតួនាទីរបស់សារការីក៏បានបញ្ចាប់ទៅតាមនឹងផងដែរ ។ យ៉ាងណាមិញអ្នកប្រតិបត្តិមតកសាសន៍ត្រូវប្រតិបត្តិដោយសុចរិត និងមានភាពស្មោះត្រង់។ ហើយការបញ្ចាប់តួនាទីក្នុងការប្រតិបត្តិមតកសាសន៍យ៉ាងណានោះ យើងគប្បីយល់៖ អ្វីទៅ ការអនុវត្តចប់ (៣.៣.១) ការលាឈប់ (៣.៣.២) ការបញ្ឈប់ ( ៣.៣.៣) និង អានុភាពនៃការប្រតិបត្តិមតកសាសន៍ ( ៣.៣.៤)

### ៣.៣.១. ការអនុវត្តចប់

នៅពេលដែលសារការីប្រតិបត្តិមតកសាសន៍ និងបានបំពេញនូវតួនាទីរបស់ខ្លួនទៅតាមលក្ខខណ្ឌដែលបានកំណត់ក្នុងខ្លឹមសារនៃមតកសាសន៍ និងគោរពតួនាទីជាអ្នកប្រតិបត្តិមតសាសន៍ រួចអស់ហើយ ការអនុវត្តមតកសាសន៍នេះក៏បានបញ្ចប់ ហើយបើការអនុវត្តមានសភាពត្រឹមត្រូវ

សុចរិត ស្មោះត្រង់ សច្ចភាព ហើយថែមទាំងមានសីលធម៌ទៀតនោះ ការអនុវត្តនូវមតកសាសន៍នោះក៏ត្រូវបានចប់ នូវពេលដែល មតិកនោះបានចែកទៅឲ្យសន្តតិជន និងជនដែលពាក់ព័ន្ធផលប្រយោជន៍រួចរាល់ ។ ដូចនេះការអនុវត្តមតកសាសន៍ក៏ត្រូវបានបញ្ចប់ផងដែរ ។

### ៣.៣.២. ការលាឈប់

បើមានមូលហេតុត្រឹមត្រូវ សារការី អាចលាឈប់ពីភារកិច្ចបាន ដោយទទួលការអនុញ្ញាតពីតុលាការ[36]។ មូលហេតុត្រឹមត្រូវអាចមានច្រើនសណ្ឋាន ដូចជា ការមានជម្ងឺរាំរ៉ៃ ការជាប់ទៅបំពេញបេសកម្មនៅបរទេសមានរយៈពេលវែង ឬមានភាពមមាញឹកនឹងការបំពេញការងារផ្ទាល់ខ្លួនជាច្រើន និងមានការកាប់មុខងារមួយដែលមានភាពមមាញឹកហួសហេតុ ជាអាទិ៍[37]។ ការអនុញ្ញាតឲ្យសារការីលាឈប់ពីភារកិច្ចនេះ គឺមានភាពចាំបាច់ណាស់ ដោយសារតែវាបានបញ្ចៀសនូវផលវិបាកគតិយុត្តិដល់សន្តតិជន ឬអច្ច័យលាភី ក៏ដូចជាអ្នកពាក់ព័ន្ធទៅនឹងផលប្រយោជន៍ផងដែរ ។

### ៣.៣.៣. ការបញ្ឈប់

បើសារការីជាអ្នកប្រតិបត្តិមតកសាសន៍ បានធ្វេសប្រហែស ក្នុងការបំពេញនូវភារកិច្ច ឬបើមានមូលហេតុត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការឲ្យបញ្ឈប់គាត់នោះបាន[38] ។ មូលហេតុនៃការបញ្ឈប់មានដូចជា ការបាត់ខ្លួនរបស់សារការីជាអ្នកប្រតិបត្តិមតកសាសន៍ ការមិនយកចិត្តទុកដាក់នឹងភារកិច្ចរបស់ខ្លួន ការគៃបំបាត់ទ្រព្យសម្បត្តិរបស់មតកជន ការជាប់ពន្ធធានាគារ ភាពខ្ជិលច្រអូសនៃការបំពេញមុខងារ និងមានជម្ងឺរយៈពេលវែងដែលជាឧបសគ្គក្នុងការប្រតិបត្តិ ជាអាទិ៍[39] ។

### ៣.៣.៤. អានុភាពនៃការប្រតិបត្តិមតកសាសន៍

ជាគោលការណ៍ នៅពេលដែលមានវត្តមាននៃមតកសាសន៍ ហើយសារការីជាអ្នកប្រតិបត្តិមតកសាសន៍ត្រូវបានកំណត់ដើម្បីធ្វើការប្រតិបត្តិ នោះសន្តតិជនពុំអាចចាត់ចែងមតិក ឬធ្វើសកម្មភាពផ្សេងទៀតដែលនាំឲ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ។ ហើយប្រសិនបើសន្តតិជនបានធ្វើសកម្មភាពទាំងនេះ វាពុំមានអានុភាពនោះទេ[40]។ ហេតុដូចនេះហើយ បានជា

[36] មាត្រា ១២២៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[37]ក្រសួងយុត្តិធម៌, ២០០៩, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៦ គន្ថីទី៨-ទី៩*, ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

[38] មាត្រា ១២២៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[39]ក្រសួងយុត្តិធម៌, ២០០៩, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៦ គន្ថីទី៨-ទី៩*, ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

[40] មាត្រា ១២២១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

មាត្រា ១២២៣ នៃក្រមរដ្ឋប្បវេណី បានកំណត់ថា អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាពក្នុងនាមជាអ្នកប្រតិបត្តិមតកសាសន៍ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិ ហើយសកម្មភាពដែលអ្នកប្រតិបត្តិបានធ្វើជាមុខនាទី ត្រូវមានអានុភាពផ្ទាល់ចំពោះសន្តតិជន ។ ដូចបានដឹងហើយថា សន្តតិ-ជនជាប្រធាននៃមតិក រីឯសារការីអ្នកប្រតិបត្តិមតកសាសន៍ គឺមានសិទ្ធិក្នុងការគ្រប់គ្រង និងចាត់ចែង រាល់សកម្មភាពដែលខ្លួនធ្វើបានធ្វើ គឺមានអានុភាពផ្ទាល់ចំពោះសន្តតិជន ។

ឧទាហរណ៍៖ មតកជនបានធ្វើអច្ច័យទាននូវដីមួយកន្លែងឲ្យទៅអច្ច័យលាភីដែលជាក្មួយរបស់ខ្លួន ។ ការធ្វើអច្ច័យទាននោះ នឹងនាំឲ្យសន្តតិជនរបស់មតកជននេះក្លាយជាទៅជាកូនបំណុលរបស់អច្ច័យលាភី ហើយសន្តតិជនត្រូវអនុវត្តករណីយកិច្ចចំពោះអច្ច័យលាភីនោះ ។ ហេតុដូចនេះហើយ ប្រសិនបើមានសារការីអ្នកប្រតិបត្តិមតកសាសន៍ នឹងក្លាយជាអ្នកអនុវត្តជំនួសសន្តតិជន ហើយការអនុវត្តនោះផងដែរមានអត្ថន័យថាសន្តតិជនបានអនុវត្តករណីយកិច្ចរបស់ខ្លួនចំពោះម្ចាស់បំណុលដែលជាអច្ច័យលាភីនោះផងដែរ ដោយហេតុថាអ្នកប្រតិបត្តិមតកសាសន៍គឺជាអ្នកតំណាងរបស់សន្តតិជន ។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងដែលបានបង្ហាញនៅការអត្ថាធិប្បាយខាងលើរួចមកហើយ អំពីការចាប់កំណើតជាថ្មីម្តងទៀតនៃវិជ្ជាជីវៈសារការីក្នុងនីតិរដ្ឋថ្មីនេះ ហើយថែមទាំងធ្វើឲ្យដឹង ទាក់ទងនឹង មុខងារ សិទ្ធិ កាតព្វកិច្ច ហើយជាពិសេសនោះធ្វើដឹងពីតួនាទីសារការីក្នុងលិខិតមតកសាសន៍មួយចំនែកទៀតផងដែរ ។ ហេតុដូចនេះហើយសារការីចំនួនតិចតួចនៅឡើយ ហើយវិសាលភាពរបស់សារការីនេះទៀតសោតនូវមិនទាន់មានភាពទូលំទូលាយនៅឡើយទេ រហូតមកដល់នេះមានប្រជាពលរដ្ឋប្រមាណមិនដល់ ៩០ភាគរយផងដែលបានស្គាល់ និងយល់ដឹងអំពីវិជ្ជាជីវៈសារការី ហើយស្របពេលដែលសារការីមានចំនួនកើតឡើងជាបន្តបន្ទាប់ ហើយក៏មានការកកើតនូវមន្ទីសារការីជាច្រើនផងដែរ ប៉ុន្តែនៅតែមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការក្នុងពេលបច្ចុប្បន្ននេះនោះទេ ។

សារការី គឺជាមន្ត្រីសាធារណៈដែលទទួលបានប្រតិភូតកម្មអំណាចពីរាជរដ្ឋាភិបាលដែលមានតួនាទីសំខាន់ក្នុងការតាត់តែងលិខិតគតិយុត្តដោយសារការី និងបានផ្តល់ការពិគ្រោះយោបល់ និងបញ្ជាក់នូវបំណងពិតរបស់គូរភាគីទាំងសងខាង ពីដើមហើយនិងពន្យល់ហេតុផលទាំងនោះ ។ សារការី ជាមន្ត្រីសាធារណៈដែលអនុវត្តវិជ្ជាជីវៈសេរី ដែលមានសេរីភាពក្នុងការទទួលយកអតិថិជនដើម្បីបំរើសេវារបស់ខ្លួន ។ ហើយតួរយ៉ាងសារការី ក៏មានតួនាទីយ៉ាងសំខាន់ផងដែរក្នុងលិខិតមតក-សាសន៍ដូចជា ហើយតួនាទីរបស់សារការីក្នុងលិខិតមតកសាសន៍ដែលតួនាទីដ៏សំខាន់នោះ មានតួនាទីក្នុងការតាក់តែងនូវលិខិត តួនាទីក្នុងការតម្កល់ និងតួនាទីក្នុងប្រតិបត្តិមតកសាសន៍ ។ ហើយបច្ចុប្បន្នសារការីបានដើរតួយ៉ាងសំខាន់ ក្នុងវិស័យច្បាប់ ជាពិសេសនៅក្នុងទំនាក់ទំនង គ្រួសារ និងទំនាក់ទំនងគតិយុត្ត ដែលទាមទារការចូលរួមជាចាំបាច់នៃវត្តមានរបស់សារការី ។ សារការី ជាអ្នកធានាការពារផលប្រយោជន៍របស់គូភាគី ដែលបានមកពឹងពាក់ខ្លួនឲ្យជៀសផុតពីការកេងប្រវ័យការក្លែងបន្លំ ការឆបោក និងល្បិចកលទុច្ចរិតគ្រប់បែបយ៉ាង និងតាមរូបភាពធ្វើជាលិខិតស្នាម ឬលិខិតផ្សេងៗ ។ ដោយលិខិតយថាភូត ដែលសារការីបានចារឹកឡើងជូនដល់គូភាគី ដូចជា៖ មតក-សាសន៍ និងលិខិតស្នាមផ្សេងទៀត គឺមានការផ្តល់ប្រឹក្សាយោបល់ពីសំណាក់សារការី ហើយលក្ខណៈច្បាសលាស់និងមានភាពទទួលខុសត្រូវខ្ពស់ក្នុងការតាក់លិខិតរបស់ខ្លួន ដោយត្រូវពិនិត្យយ៉ាងម៉ត់ចត់ រួមទាំងមានការទុកដាក់នឹងរក្សាទុក និងរក្សាការសម្ងាត់យ៉ាងត្រឹមត្រូវបំផុត ដែលអាចនិយាយបានថានេះជាកាតព្វកិច្ចរបស់សារការីផងដែរ ។ ហើយយ៉ាងណាមិញសារការីគឺមានសារៈសំខាន់ណាស់ ក្នុងការរក្សាសណ្តាប់ធ្នាប់ និងស្ថេរភាពក្នុងសង្គម ពីព្រោះបើយើងពិនិត្យទៅលើ

តួនាទីរបស់សារការីគឺមានភាពរឹងមាំក្នុងការពង្រឹងស្ថានភាពគតិយុត្តទាក់ទង និងលិខិតមតសាសន៍ ដែលច្បាប់បានប្រគល់ឲ្យវិជ្ជាជីវមួយនេះ ។

ជាចុងក្រោយ យើងអាចសន្និដ្ឋានបានថាសារការីជាវិជ្ជាជីវៈមួយ ដែលសង្គមនៃការរស់នៅបច្ចុប្បន្នត្រូវការជាចាំបាច់មិនតែប៉ុណ្ណោះ សិទ្ធិ និងកាតព្វកិច្ចរបស់កសារការីបានដើរតួយ៉ាងសំខាន់បំផុតនៅក្នុងវិស័យច្បាប់ ដែលជួយជំរុញក្នុងការអភិវឌ្ឍនៃការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវនិងមានសមតភាព តម្លាភាព យុត្តិធម៌ ភាពឆាប់រហ័ស និងផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការពឹងពាក់ផងដែរ ។ តួយ៉ាងតួនាទីសារការីក្នុងលិខិតមតកសាសន៍ពិតជាមានសារៈសំខាន់ណាស់ក្នុងការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធិភាព តាមរយៈការកាត់បន្ថយពាក្យបណ្តឹង នឹងភាពស្មុកស្មាញនៃការជុំនុំជំរះ ក្នុងបណ្តឹងរដ្ឋប្បវេណី ពិសេសការជួយជំរុញអោយការប្រកបនូវប្រសិទ្ធិភាព ទំនុបចិត្តដោយការបង្កើនភាពស្របតាមច្បាប់ ។

# អនុសាសន៍

ក្រោយពីបានបញ្ចាប់ការសិក្សាស្រាវជ្រាវ អំពីតួនាទីសារការីក្នុងលិខិតមតកសាសន៍ ក្រុមខ្ញុំបាទបានសង្កេតឃើញថា តួនាទីសារការីក្នុងលិខិតមតកសាសន៍ ពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយជំរុញ ការអនុវត្តច្បាប់ដោយកាន់តែប្រសើរឡើង ។ ជាមួយគ្នានោះដែរ ក្រុមខ្ញុំបាទយល់ឃើញថាមានចំនុចមួយចំនួនដែលជួយជំរុញឲ្យដំណើរការក្នុងការអនុវត្តលើ តួនាទីសារការីក្នុងលិខិតមតកសាសន៍ និងមានភាពល្អប្រសើរជាងពេលបច្ចុប្បន្ននេះដែលមានការរៀបរាប់ដូចខាងក្រោមៈ

សារការី គឺជាវិជ្ជាជីវៈមួយ ដែលប្រជាពលរដ្ឋភាគច្រើនពុំទាន់បានយល់ដឹងអំពី តួនាទីរបស់សារការីណាស់ ដោយសារវិជ្ជាជីវៈនេះទើបនឹងចាប់កំណើតជាថ្មីម្តងទៀត ក្នុងនីតិរដ្ឋថ្មីនេះ ដូចនេះហើយស្ថាប័នពាក់ព័ន្ធ គួរតែបង្កើតការផ្សព្វផ្សាយគ្រប់រូបភាពទាក់ទងនឹងអត្ថប្រយោជន៍ដែលភាគីទទួលបានពី ការទទួលសេវាកម្ម ការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់សារការី ទៅដល់ប្រជាពលរដ្ឋទាំងអស់ ។ ម៉្យាងទៀតទោះបីជាក្នុងពេលបច្ចុប្បន្ននេះ សារការីមានចំនួនកើនឡើងជាបន្តបន្ទាប់ពិតមែនប៉ុន្តែមិនទាន់ឆ្លើយតបទៅនឹងតម្រូវការក្នុងពេលបច្ចុប្បន្ននោះទេ ហើយបើយើងពិនិត្យមើលការសារីដែលបានឆ្លងកាត់ការបណ្តុះបណ្តាលចេញពីសាលាភូមិន្ទសារការី នៃរាជបណ្ឌិតសភាវិជ្ជាជីវៈទើបតែមានចំនួនតិចនៅឡើយទេ ដើម្បីឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្ន ស្ថាប័នរដ្ឋគួរតែមានការបណ្តុះបណ្តាលសារការីបន្ថែមទៀត ដើម្បីឆ្លើយតបនិងតម្រូវការរបស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងស្របតាមគោលការណ៍កំណែទម្រង់វិមជ្ឈការ របស់រាជរដ្ឋាភិបាល ។ បន្ថែមពីនេះ ស្ថាប័នពាក់ព័ន្ធគួរតែធ្វើការផ្សព្វផ្សយនូវតួនាទីសារការីឲ្យមានសភាពទូលំទូលាយ និងជួយសម្រួលដល់នីតិវិធីគតិយុត្តនៃច្បាប់ឲ្យកាន់តែមានប្រសិទ្ធិភាព ក្នុងការអនុវត្តនូវតួនាទីរបស់សារការីក្នុងពេលបច្ចុប្បន្ន ។ មិនតែប៉ុណ្ណោះប្រទេសកម្ពុជាយើងពុំទាន់មាន បទប្បញ្ញត្តិស្តីពីសារការីនោះទេ នោះជាផលពិបាកមួយដែលធ្វើឲ្យសារការីពិបាកក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន និងស្ថាប័នពាក់ព័ន្ធមួយចំនួន ពុំទាន់ឃើញធ្វើការគិតគូ និងពិចារណាក្នុងការពន្លឿនការអនុម័ត សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈសារការី ដើម្បីងាយស្រួលក្នុងការអនុវត្តនូវតួនាទីសារការីក្នុងនីតិរដ្ឋ។

ពួកយើងសង្ឃឹមថា តួនាទីសារការីនេះនឹងអាចអនុវត្តបានល្អ និងទទួលបានជោគជ័យក្នុងការបំពេញនូវសកម្មភាពរបស់ខ្លួននាពេលអនាគត ។ ហើយពួកយើង សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះការយកចិត្តទុកដាក់ ក្នុងការអានសៀវភៅរបស់ពួកយើងតាំងពីដើមរហូតដល់ចប់ ។